# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ប៊ុន ពិន ភេទប្រុស អាយុ៥៨ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ«យោធាកងពល៨០៥»
## កើតនៅភូមិក្តាមពុក ឃុំសេណារីឧត្តម ស្រុកព្រះស្តេច ខេត្តព្រៃវែង
## សព្វថ្ងៃរស់ ភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ សោម ប៊ុនថន និង ឌី ខាំបូលី
## ០២:០៩ :២៧
## ៥៨ ទំព័រ

ថនៈ ជាដំបូង ខ្ញុំសុំអនុញ្ញាតសួរពូ! លោកពូឈ្មោះអីដែរ?

ពិនៈ ខ្ញុំឈ្មោះ ប៊ុន ពិន ។

ថនៈ សព្វថ្ងៃអាយុប៉ុន្មានពូ?

ពិនៈ ១៩៥៥ ឆ្នាំកំណើត ។

បូលីៈ ៥៨ ឬក៏៦៨?

ថនៈ ៥៨ ។

ពិនៈ ៥៨ ទៅ៥៩ ។ ចូលនិវត្តន៍ហើយ ។

ថនៈ ស្រុកកំណើតនៅភូមិឃុំអីដែរពូ?

ពិនៈ ខ្ញុំស្រុកកំណើតនៅឃុំសេណារីឧត្តម ស្រុកព្រះស្តេច នៅភូមិក្តាមពុក ខេត្តព្រៃវែង ។

ថនៈ បច្ចុប្បន្ន ពូនៅភូមិឃុំអីដែរពូ?

ពិនៈ នៅភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ថនៈ ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ពិនៈ ខ្ញុំបងប្អូនមាន៨នាក់ ។

ថនៈ ពូកូនទីប៉ុន្មាន?

ពិនៈ ខ្ញុំកូនទី៧ហើយ បន្ទាប់ពីប្អូនពៅស្រី ។

ថនៈ ពូអាចរៀបរាប់បងប្អូនបានទេពូ? កូនទី១ កូនទី២ ទី៣?

ពិនៈ បានតា! ទី១ ប្រុស ប៊ុនវល្លិ៍ ។

ថនៈ គាត់នៅរស់ទេ?

ពិនៈ នៅ!

ថនៈ គាត់នៅឯណាដែរទៅ?

ពិនៈ នៅឯស្រុកកំណើត ។

ផនៈ ព្រៃវែង?

ពិនៈ បាទ! ព្រៃវែង ។

ផនៈ ទី២?

ពិនៈ ទី២ ប៊ុន សែ ។

ផនៈ ប្រុសដែរអីពូ?

ពិនៈ ស្រី! បងស្រី ។

ផនៈ គាត់នៅ?

ពិនៈ គាត់នៅស្រុកកំណើតដែរ ។

ផនៈ ទី៣ពូ?

ពិនៈ ទី៣ បងស្រីដែរ ប៊ុន ឡៃ ។

ផនៈ នៅព្រៃវែងដែរអីពូ?

ពិនៈ បាទៗ! ហ្នឹងហើយនៅព្រៃវែង ។

ផនៈ ទី៤ពូ?

ពិនៈ ប៊ុន ផន, ប្រុស ។

ផនៈ ប្រុសពូ?

ពិនៈ ប្រុស, គាត់នៅព្រៃវែងដែរ ។

ផនៈ ទី៥?

ពិនៈ ទី៥ ប៊ុន ផាន ។

ផនៈ ប្រុស?

ពិនៈ ប្រុស! ស្លាប់ហើយគាត់ ។

ផនៈ ស្លាប់ដោយសារអីពូ?

ពិនៈ គាត់សស្លាប់ដោយសារជំងឺ ។

ផនៈ ឆ្នាំប៉ុន្មានពូ?

ពិនៈ គាត់ស្លាប់ប៉ុន្មានហើយទេនេះ ។

ផនៈ ទើបស្លាប់ថ្មីនេះៗ ។

ពិនៈ បាទ! ទើបតែស្លាប់ឥលូវដែរទេ ។

ផនៈ ទី៦ពូ?

ពិនៈ ទី៦ ប៊ុន ម៉ា ។

ថនៈ ប្រុស?

ពិនៈ ប្រុស!

ថនៈ គាត់នៅរស់ទេ?

ពិនៈ រស់ ។ នៅក្បែរខ្ញុំរាល់ថ្ងៃ ។

ថនៈ នៅទំនប់ដាច់?

ពិនៈ បាទ! នៅទំនប់ដាច់ ។

ថនៈ ទី៧ពូ?

ពិនៈ បាទ!

ថនៈ ទី៨?

ពិនៈ ទី៨ប្អូនស្រី, ប៊ុន លួន, នៅរស់ ។

ថនៈ គាត់នៅ?

ពិនៈ គាត់នៅស្រុកកំណើត ខេត្តព្រៃវែង ។ មក! ទៅមកៗដែរ ។

ថនៈ ពូឧស្សាហ៍ទៅស្រុកអីទេ?

ពិនៈ ទៅ! ទៅធ្វើបុណ្យទៅធ្វើអី ធ្វើអីចេតិយធ្វើអី ។

ថនៈ ឪពុកម្ដាយពូនៅរស់ទេពូ?

ពិនៈ ស្លាប់អស់ហើយ ស្លាប់មិនបានជួបមុខផង ។

ថនៈ គាត់ស្លាប់ជំនាន់ណា?

ពិនៈ ក្នុងឆ្នាំ៧៩ ម្ដាយខ្ញុំ ។

ថនៈ ហ៎ូ! បែកខ្មែរក្រហមហ៎ពូ?

ពិនៈ ម្ដាយ៧៩ ។

ថនៈ ហើយឪពុកឈ្មោះអីវិញ?

ពិនៈ ប៊ុន ពៅ ។

ថនៈ ម្ដាយ?

ពិនៈ បួយ ដាន ។

ថនៈ គាត់នៅរស់ទេពូ?

ពិនៈ ម្ដាយស្លាប់បាត់ហើយ ។

ថនៈ គាត់ស្លាប់ជំនាន់ណាដែរ? គាត់នៅរស់ទេម្ដាយ?

ពិនៈ ស្លាប់! ស្លាប់ហើយ ។

ថនៈ គាត់ស្លាប់ជំនាន់ណាដែរ?

ពិនៈ គាត់ស្លាប់៧៩ ។

ថនៈ ៧៩ ដូចឪពុកពូដែរ?

ពិនៈ អត់ទេ! ឪពុកស្លាប់ក្រោយទេ ។ ខ្ញុំសួរទៅ ឪពុកស្លាប់១៩៨៥ ។

ថនៈ ពេលពូរត់មកនេះហើយ?

ពិនៈ ខ្ញុំរត់មកនេះហើយ ខ្ញុំនៅជាយដែន ។

ថនៈ ពូកាលពីតូចពូរៀនសូត្រនៅណាដែរ?

ពិនៈ រៀនមុនដំបូង ចូលរៀននៅសិរីសាគរដូនស្តើង ទៅនៅវត្ត សាលាពីដើមមានតែវត្តហ្នឹងឯង ឪពុកម្តាយយកទៅផ្ញើរនៅវត្តហ្នឹង សិរីសាគរដូនស្តើង ។

ថនៈ នៅភូមិក្តាមពុកហ្នឹងអី?

ពិនៈ បាទ! វត្តហ្នឹងនៅនេះ នៅភូមិប្រលោះទីហ្នឹង នៅភូមិធ្នង់ផង នៅភូមិក្បៀងផង ។

ថនៈ ពូរៀនបានប៉ុន្មានឆ្នាំដែរ?

ពិនៈ រៀននៅហ្នឹង ចប់ត្រឹមថ្នាក់ទី១០វត្តហ្នឹង ហើយបានបន្តទៅរៀននៅសាលាមួយទៀតនៅសាលាវត្តទ្រាទៀត ។

ថនៈ ពូចប់ត្រឹមថ្នាក់ទី១០ហ្នឹង?

ពិនៈ ចប់ត្រឹមថ្នាក់ទី៨ ។

ថនៈ នៅឆ្នាំប៉ុន្មានពូ?

ពិនៈ នៅឆ្នាំ៧០ ។

ថនៈ ១៩៧០?

ពិនៈ បាទ!

ថនៈ បន្ទាប់មកត្រូវបន្តទៅរៀន?

ពិនៈ អត់! អត់មានបានបន្តទេ ។ ក្រោយមកមានការរត់ប្រហារសម្តេចសីហនុ ។

ថនៈ ដល់ប្រហារ ពូឈប់រៀន ។ ម៉េចបានពូឈប់រៀន?

ពិនៈ ហ៊ូនែក កាលហ្នឹងរដ្ឋប្រហារនៅតាមស្រុកជនបទ វាមានសង្គ្រាមហើយ ដល់ពេលឈប់រៀនហ្នឹងពេលរដ្ឋប្រហារម្តាយឲ្យទៅបួស ។

ថនៈ ទៅបួសនៅវត្តណាពូ?

ពិនៈ បួសនៅវត្តដូនស្តើងដែរ បួសនៅវត្តហ្នឹងកាលទៅរៀននោះ ។

ថនៈ លោកពូបួសបានប៉ុន្មានឆ្នាំ?

ពិនៈ ដូចបាន១វស្សាដាង, បួសបានតិច ។

ថនៈ បន្ទាប់ពីសឹកហើយលោកពូធ្វើអីទៀតកាលហ្នឹង?

ពិនៈ បន្ទាប់ពីសឹកហើយ ទៅចូលរួមនៅព្រៃម៉ាគី ។

ថនៈ ចូលបដិវត្តន៍?

ពិនៈ បាទ! ចូលបដិវត្តន៍ ។

ថនៈ ពូមានដឹងថ្ងៃខែឆ្នាំចូលទេ?

ពិនៈ ឆ្នាំកាលចូលហ្នឹង ដូចឆ្នាំ៧០ ,៧២ហ្នឹង ។

ថនៈ ខែប៉ុន្មានពូ?

ពិនៈ អីយ៉ា! មិនដឹងខែប៉ុន្មានទេ! មិនចាំខែផង, ចូលហ្នឹងខែនេះ ខែចុងរដូវដែរហ្នឹង ។ ដូចរដូវចម្រូត ច្រូតស្រូវដាក់ជង្រុកហើយ ។

ថនៈ ពូចូល ចុលតាមរយៈនរណាគេពូ?

ពិនៈ តាមរយៈបង ។

ថនៈ បងបង្កើតពូ?

ពិនៈ បងជីដូនមួយមកយកទៅ ។

ថនៈ គាត់ធ្វើអីដែរ?

ពិនៈ គាត់, កាលហ្នឹងគាត់នៅយោធារបស់តំបន់២៤ ។

ថនៈ ខាងណាខាងព្រៃវែង, ២៣ ខាងស្វាយរៀង ។ គាត់យោធាតំបន់ គាត់ឈ្មោះអីដែរ?

ពិនៈ បែកបងគាត់ បងពុម, ត្រកូលដែរប៊ុន ពុម ។

ថនៈ គាត់នៅរស់ទេ?

ពិនៈ គាត់ស្លាប់ហើយ ។ គាត់ស្លាប់ពេលហ្នឹង ដែលខ្ញុំដឹងនោះ កាលហ្នឹងគាត់ហៅខ្ញុំទៅរៀន ហើយក៏បាត់រហូត សន្មត់ថា ស្លាប់តែម្ដង ។

ថនៈ ខាងណាហៅ?

ពិនៈ កាលហ្នឹងដូច មិនដឹងខាងណាទេ ប៉ុននៅតំបន់ហ្នឹងគេត្រូវហៅទៅរៀនមេទាំងអស់ គាត់កាលទៅគាត់នៅវរសេនាតូចដែរ ។ នៅវរសេនាតូច នៅប្រចាំព្រំដែនខាងត្បូងហ្នឹង គាត់នៅ យ-៦ មេបញ្ជាការយ-៦ហ្នឹងឯង ។

ថនៈ ហើយពូចូលដំបូងចូលនៅឯណាវិញពូ?

ពិនៈ ចូលដំបូងចូលនៅស្រុកកណើតនៅឯ២៤ ។

ថន៖ បន្ទាប់ពីចូលហើយ ពូបញ្ជូនទៅណា?

ពិន៖ បញ្ជូន គេបញ្ចូលក្រោយមកគេបញ្ចូលទៅកង៨០៥ នៅអង្គភាពយោធាដដែរ ។

បូលី៖ កងពល៨០៥?

ពិន៖ បាទ!

បូលី៖ នៅឆ្នាំប៉ុន្មាន?

ពិន៖ អ៊ូ! អាហ្នឹងនៅឆ្នាំ ៧៦ ។

បូលី៖ អ៊ូ! ក្រោយ៧៥មកទេ?

ពិន៖ បាទ!

បូលី៖ អំបាញ់ប៉ុន ថន ចង់ជម្រាបសួរពូ ពេលដែលចូលបដិវត្តន៍ ។

ពិន៖ កាលនៅមុនឆ្នាំ៧៥ នៅក្នុងអង្គភាពកងទ័ពរបស់តំបន់ហ្នឹងឯង ។

ថន៖ អង្គភាពកងតំបន់២៨?

ពិន៖ បាទ! ២៨ ។

ថន៖ កាលហ្នឹងគណៈតំបន់ពីណាគេ?

ពិន៖ គណៈតំបន់ មុនដំបូងតាឈូក ហើយក្រោយមកនែកបានតាឈូកឡើងទៅរៀនបាត់ទៅ បានឡើងតាចេងម្តង ។

ថន៖ តាឈូកនៅហ្នឹងអី?

ពិន៖ បាទ! តាឈូក ឈ្មោះគាត់គេហៅ តាឈូកៗណាស់ ។

ថន៖ តាជ័យ ។

ពិន៖ បាទ! តាជ័យសុទ្ធតែគណៈតំបន់ហ្នឹង ។

ថន៖ គាត់ស្អីឈ្មោះ?

ពិន៖ អត់ទេ អត់ចាំនាមត្រកូលទេ ហៅតាជ័យៗ ។

ថន៖ ពូនៅអង្គភាពតំបន់រហូតដល់បែកឆ្នាំ៧៥?

ពិន៖ បាទ! ក្រោយឆ្នាំ៧៥ នៅអង្គភាពតំបន់ហ្នឹងរហូតហ្នឹងឯង ។

ថន៖ ចឹងដំបូងពូចូលអត់ទាន់មានបែងចែកជា?

ពិន៖ អត់នៅក្នុងកងពល នៅក្នុងវររបស់កងទ័ពតំបន់ហ្នឹង គេចែកជាវរៈ មានយ-របស់គេណា ។

ថន៖ មានប៉ុន្មានពូវរៈ?

ពិន៖ មាន! ដូចមានយ-៥,មានយ-៨, មានយ-៦ តាមនេះឆ្ងាប់ ។

ថន៖ មានបីយ-?

ពិនៈ មានបីយ-ៗ

ថនៈ ចុះពូដល់ឆ្នាំ៧៥ហ្នឹងពូ នៅទៅណាទៀតពូ?

ពិនៈ ក្រោយឆ្នាំ៧៥ នៅព្រំដែនវៀតណាម ។

ថនៈ ខាងណាវិញពូ?

ពិនៈ នៅម្តុំអន្លង់ ម្តុំសមរភូមិត្រពាំងព្រាយ ភូមិខ្មែរ ។

ថនៈ ស្រុកអីគេ?

ពិនៈ ហ៊ូ! អាហ្នឹងឃុំចាម ស្រុកកំពង់ត្របែក ប៉ុននៅព្រំប្រទល់វៀតណាម ។

ថនៈ នៅខាងណា តាំងគោកវិញហ៊ឺពូ?

ពិនៈ អត់ទេ!

ថនៈ ចូលទៅតាមតាំងគោក ឬក៏នៅនែកនេះ?

ពិនៈ គេបញ្ជូនកងទ័ពទៅនៅព្រំដែនវិញ ទៅនៅម្តុំភូមិខ្មែរ ប៉ុន្តែឈរជើងទៅនៅអន្លង់ ភូមិចាប ស្រុកកំពង់ត្របែក ។

បូលីៈ ពេលហ្នឹងគេរៀបចំកងពលនៅ?

ពិនៈ ហ៊ូ! អាហ្នឹងគេបញ្ចូលកងពលហើយ ។

បូលីៈ លេខប៉ុន្មានពូ?

ពិនៈ កងពលលេខ៨០៥ ។

បូលីៈ ពីណាគេមេកងពល?

ពិនៈ មេកងនែក៏ លេខាកងពលបងហួយ ។

បូលីៈ ហួយ?

ពិនៈ បាទៗ! ហើយដល់មេបញ្ជាការបងសេន មេបញ្ជាកាកងពល ។

ថនៈ មេបញ្ជាកាសុខហួយ?

ពិនៈ មេបញ្ជាកាសុខ សេនៗ បងហួយ គាត់លេខា ឥលូវគាត់ទៅធ្វើអាចារ្យវត្តហើយ ប្រពន្ធក៏មិនយក ។

បូលីៈ ហួយ!

ពិនៈ គាត់នៅស្រុកបាភ្នំដែលគា បងហួយ ដល់ឥលូវទៅសួរសុខទុក្ខគាត់ទៅ ថាគាត់នៅធ្វើអាចារ្យវត្តណា មិនយកប្រពន្ធមិនយក ។

ថនៈ ខុសគ្នាយ៉ាងម៉េចពូ លេខា និងមេបញ្ជាកាហ្នឹង?

ពិនៈ ហ៊ូ! កាលនោះចង់និយាយថាមេបញ្ជាការគ្រប់គ្រងបញ្ជីកងកម្លាំងលើសមរភូមិទាំងអស់ណា ដល់លេខាដូចទទួលផ្សព្វផ្សាយនយោបាយចិន ដល់អាខាងពង្រីង បង្រៀនហ្នឹង ។

បូលីៈ មួយណាធំជាងបើយើងគិតពីឋានៈ?

ថនៈ ឋានៈ លេខាធំជាង សម័យនោះ ។

បូលីៈ ចុះអំណាចពីណាខ្លាំងជាង?

ពិនៈ អំណាចពីរហ្នឹង នៅប្រហាក់ប្រហែលគ្នាទេ មេបញ្ជាការ និងលេខាហ្នឹងសហការគ្នាបានដូចប្រធានហើយហ្នឹងអនុចឹងណ៎ា ។

បូលីៈ ចុះអ្នកណាដែលមានឥទ្ធិពលលើកងទ័ពជាង?

ពិនៈ ឥទ្ធិពល លេខាហ្នឹងហើយ គាត់គ្រប់គ្រងរួម ។

បូលីៈ មិនមែនមេបញ្ជាការនេះ មានឥទ្ធិពលលើកងទ័ពជាងទេ?

ពិនៈ បាទ! មេបញ្ជាការគាត់សម្រេចបញ្ជារាល់បណ្ដាលសមរភូមិទាំងអស់?

បូលីៈ នៅក្នុងមួយកំណាត់(ស្ដាប់ពុំបាន) ក្រែងមានមនុស្ស៣នាក់?

ពិនៈ កាលនោះមាន៥ សាខារបស់កងពលហ្នឹង ។ យ- ក៏អីចឹង តាម យ-ក៏មាន៥រូបដែរ ។

បូលីៈ នៅក្នុងកងពល៨០៥ហ្នឹងមានប៉ុន្មានវរសេនាធំ?

ពិនៈ កងពល៨០៥ មានប៉ុន្មានទេ ដូច៣វរៈ ។

បូលីៈ បីវរៈ ។

ពិនៈ យ-ចំណុះ ដូចខ្ញុំបញ្ជាក់ខាងដើមមិញហ្នឹងចឹង យ-៥, យ-៦,យ-៤ ។

បូលីៈ ចឹងបានន័យថាកងពលបង្កើតចេញពីវរៈ អស់នេះទេអីចឹង?

ពិនៈ បាទៗ! ហ្នឹងហើយបញ្ចូល ។ ចង់និយាយថា បញ្ចូលកងទ័ពទៅបំពេញក្នុងកងពលទាំងអស់តែម្ដង ពេលហ្នឹង ។

បូលីៈ កងពលនោះ ជាកងពលរបស់ភូមិភាគបូព៌ា ឬក៏មជ្ឈិម?

ពិនៈ កងពលរបស់ភូមិភាគ ។

បូលីៈ របស់តា០៥ ។

ពិនៈ បាទ! ចំណុះរបស់ភូមិភាគទាំងអស់ ។

បូលីៈ មិនមែនរបស់មជ្ឈិមទេ?

ពិនៈ មិនមែនរបស់មជ្ឈិមទេ ។

បូលីៈ ហូយហ្នឹង គាត់កងពលលេខាតាំងពីដើម ឬគាត់?

ពិនៈ គាត់ទើបតែប្រកាសឡើងលេខាកងពល ទើបតែប្រកាសប្រជាច់បញ្ចូលកងពល៨០៥ហ្នឹង ដែលមានបងសេមបញ្ចូលពីខាងកំពង់ចាមទៅ សេមហ្នឹងគាត់នៅខាងកមពង់ចាមស្រុកកំណើត គាត់នៅខាងដូចខាងខេត្តក្រចេះ ហ៎កំពង់ចាមដែរ ប៉ុន្តែឥលូវគាត់មេបញ្ជាការដែរ ។

បូលី: បូព៌ាហ្នឹងមានប៉ុន្មានកងពលសរុបទាំងអស់?

ពិនៈ អត់ដឹងទេ មិនដឹងប៉ុន្មានទេ បើដល់ភូមិភាគវាលើស ការគ្រប់គ្រងយើងនៅក្មេងផង យើងអត់ ក្តាប់បានទេ ក្តាប់តែអង្គភាពរបស់ពួកយើងតូច១ទេ ។

បូលី: ពូនៅអង្គភាពអីគេកាលហ្នឹង?

ថនៈ នៅក្នុងយ-៦ នៅជាមួយបង ។

បូលី: យ-៦?

ពិនៈ បាទ!

បូលី: នៅជាមួយបងដែរ?

ពិនៈ បងជីដូនមួយ បងពុំនោះ ។

ថនៈ បងពុំ គាត់ប្រធានយ-នោះតែម្តង?

ពិនៈ បាទ! គាត់ប្រធាន ។

បូលី: យ-ហ្នឹងស្មើរនឹងវរសេនាធំ?

ពិនៈ យ-នោះវរសេនាតូច ។

បូលី: តូចទេហ៎?

ពិនៈ បាទ!

បូលី: ចុះធំ?

ពិនៈ ធំដូចមក ង-ទេ វរសេនាធំទេ ។

បូលី: ១កងពល មាន៣វរសេនាធំ ឬប៉ុន្មាន?

ពិនៈ ១កងពល ៣, ៣មានវរសេនាធំ គាំទ្រកាំភ្លើងធំទៀត មួយវរៈទៀត អីចឹងវាដូច៤ដែរ ប៉ុន្តែ ខ្ញុំមិនចាំទេ ។

បូលី: អត់ចាំលេខ?

ពិនៈ បាទ! អត់ចាំទេ ព្រោះយើងនៅតូចកាលហ្នឹង កាលហ្នឹងយើងនៅក្មេងផង យើងមិនបានគិតអា រឿងចឹង១ គិតថាថ្ងៃណាមេប្រើទៅណាទៅហ្នឹងទៅណា ។

បូលី: ហើយតំណែងពូជាអីកាលហ្នឹង?

ពិនៈ កាលហ្នឹងយុទ្ធជន ។

បូលីៈ អត់ទាន់មានគ្រួសារទេកាលហ្នឹង?

ពិនៈ កាលហ្នឹងនៅ ។

បូលីៈ ពូកើតឆ្នាំប៉ុន្មាន?

ពិនៈ កើតហេ៎?

បូលីៈ ការ ការ!

ពិនៈ ហ៎ូ! ខ្ញុំឆ្នាំ៨០ហើយ ។

បូលីៈ ក្រោយមកទេចឹង?

ពិនៈ បាទ! ក្រោយមកជាយដែន ។

បូលីៈ ពូនៅព្រំដែនវៀតណាម ការប៉ះទង្គិច មានញីកញាប់ ឬក៏ម្ដងម្កាល?

ពិនៈ ពីមុនមិនមានការប៉ះទង្គិចទេ ដល់ពេលឆ្នាំ៧៧បានមានការប៉ះទង្គិច ប៉ះទង្គិចទៅតាមព្រំដែន មុនដំបូងយើងចង់និយាយថា វាមិនទាន់ជាញឹកញាប់ទេណា៎ ។ ដល់ពេលក្រោយមកបានមានការប្រយុទ្ធគ្នាញឹកញាប់ជាប់ជាប្រចាំហើយអាហ្នឹង ។

បូលីៈ បានន័យថារៀងរាល់ថ្ងៃ ឬក៏រាល់អាទិត្យ?

ពិនៈ វាសឹងថាវារៀងរាល់ថ្ងៃសុទ្ធហើយដល់ពេលចុងក្រោយ ប៉ុនវាអត់ចាំពេលវេលាថ្ងៃ គ្រាន់តែថា ដែលយើងធ្លាប់នៅព្រំដែនហ្នឹង ។

បូលីៈ ញឹកញាប់និយាយទៅ?

ពិនៈ បាទ!

បូលីៈ កាលដែលប៉ះទង្គិចហ្នឹងជម្លោះមកពីមូលហេតុអីតាមដែលពូដឹង?

ពិនៈ កាលហ្នឹង! មិនដឹងជាមូលហេតុអីទេកាលហ្នឹង ។ ខាងលើ ប៉ុនគ្រាន់តែជានៅការពារព្រំដែនកាលហ្នឹង វាចេះតែធម្មតាទេកាលហ្នឹងប៉ះទង្គិច វាចេញចូលអីចឹងទៅណាជាមួយវៀតណាម ។

បូលីៈ គេមានអប់រំខាងកងទ័ពហ្នឹងថាយើងត្រូវវាយជាមួយចុះចេះពីរទេកាលហ្នឹង?

ពិនៈ កាលហ្នឹងមាន មិនអត់ទេ ។ គេចង់និយាយថាអប់រំថាយើង យើងត្រូវតែការពារខ្លួន ព្រោះកុំឲ្យកងទ័ពយួនចូលឈ្លានពាន កម្ពុជាចឹងណា មានការអប់រំចឹងឲ្យយើងការពារខ្លួនអីចឹង នៅក្នុងសភាពនេះយើងចេះតែប្រយុទ្ធ ទៅមេបញ្ជាប្រយុទ្ធៗទៅ ។

បូលីៈ គេណែនាំតែប៉ុណ្ណឹងទេពូ? មានក្រៅពីការពារខ្លួន យួនឈ្លានពាន ឬក៏មានអីផ្សេងទេ?

ពិនៈ ទេ! ដូចជាមិនមានអីច្រើនទេ ។ គេចង់និយាយថាមាន ការពារខ្លួន ព្រោះយើងមិនការពារខ្លួន មិនការពារទឹកដី យួននឹងចូលឈ្លានពានទឹកដីចឹងណា មានតែការអប់រំប៉ុណ្ណឹងឯង ។

បូលីៈ គេមានបានអប់រំទាក់ទងទៅហ្នឹង បញ្ហារឿងកម្ពុជាក្រោមទេ?

ពិនៈ បញ្ហាកម្ពុជាក្រោម មេខ្លះក៏គាត់និយាយ ហើយមេខ្លះ ក៏គាត់អត់និយាយដែរ ពេលដែលគាត់ធ្វើនែក ដែលជួបជុំកងកម្លាំងអីហ្នឹងណា ធ្វើពិធីលាងកម្ម ពិធីអីផ្សេងៗចឹង។ គាត់បានលើកបញ្ហាហ្នឹងខ្លះដែរ ថាពីមុនយើងមានប្រទេសធំទូលំទូលាយចឹងណា។ ដល់ពេលក្រោយពីយើងបាត់បង់ទឹកដីដោយសារយើង ដណ្ដើមអំណាចគ្នា យើងចង់និយាយអីចឹង ដល់ចឹងធ្វើឲ្យយើងបាត់បង់ទឹកដីចឹង។ អាហ្នឹងធម្មតាទេ កាពង្រឹង។

បូលីៈ គាត់មានបានណែនាំថាយើងត្រូវតែវាយយកកម្ពុជាក្រោមមកវិញ?

ពិនៈ ពេលនោះ ដូចមានមេខ្លះ ដូចខ្ញុំបានបញ្ជាក់អីចឹង លើកបញ្ហាហ្នឹងដែរ តែមេខ្លះគាត់អត់លើកទេ បញ្ហាការពារព្រំដែនទឹកដីដែលយើងរក្សាទុកនៅក្នុងពីសម័យនែក ដែលយើងដឹងថាពីសម័យរបស់សម្ដេចសីហនុមកហ្នឹងណា ហើយមេខ្លះ គាត់ឥលូវបើយើងមានលទ្ធភាពយើងនឹងឈានទឹកដីកម្ពុជាក្រោមវិញចឹងណា។

បូលីៈ បើយើងមានលទ្ធភាព ចឹងហ៎?

ពិនៈ បាទ! ហ្នឹងហើយ។

បូលីៈ មិនមែនយើងត្រូវតែវាយយកឲ្យបានទេ?

ពិនៈ មិនមែនត្រូវវាយយកឲ្យបានទេ! ក្នុងការវាយហ្នឹង គ្រាន់តែការពារខ្លួនទេ។

បូលីៈ ចឹងគាត់មានធ្លាប់និយាយដែរ តែនិយាយក្នុងលក្ខណៈមួយដែលយើងមានលទ្ធិភាព ឬក៏និយាយថាយើងត្រូវតែវាយកឲ្យបាន ថាតាំងចិត្តវាយឲ្យបាន។

ពិនៈ ទេ! អត់មាននិយាយថាតាំងចិត្តយកឲ្យបានទេ។

បូលីៈ អត់មាននិយាយរឿងហ្នឹងទេ។

ពិនៈ អត់និយាយទេ! មិនទាន់ម៉េចមិនដឹង យើងនៅក្មេងៗ មិនសូវចាប់អារម្មណ៍ផងហ្នឹង មេនិយាយស្រួលៗ យើងប្រាជ្ញផ្សេងទៀតក៏មានដែរ។

បូលីៈ ពេលដែលវាគ្នាហ្នឹងអើ យើងដែលវាយចូលទៅដល់ដីយួនទេពូ?

ពិនៈ ចូលដល់តា!

បូលីៈ ប៉ុន្មានគីឡូពីព្រំដែន?

ពិនៈ ទេ! មិនដឹងប៉ុន្មានទេ គ្រាន់តែចូលទៅដល់វាយចូលទៅវាយផុតអាពីភូមិខ្មែរ ពីត្រពាំងព្រាម អីទៅ អាហ្នឹងអន្តភាពរបស់ខ្ញុំទេណា។ អន្តភាពរបស់គេ គេវាយចូលខ្លះគេវាយចូលដល់ផ្លូវខ្មៅ ផ្លូវកៅស៊ូ ផ្លូវអីចឹងទៅ ប៉ុន្តែយើងវាចូលមួយឆាវទេដកវិញ យើងអត់មានទៅវាយបុកនៅកន្លែងដែលយើងទៅនៅទេ។ គ្រាន់តែវាយ នៅក្នុងសភាពការពារខ្លួនដូចខ្ញុំប្រាប់បញ្ជាក់ខាងដើមអីចឹងណា។

ថនៈ ត្រពាំងព្រាមហ្នឹងនៅភូមិឃុំអីដែរពូ?

ពិនៈ នៅអីភូមិខ្មែរ ហើយនឹងត្រពាំងព្រាយនោះវានៅស្រុកយួននោះមើលទៅ ។

ថនៈ នៅស្រុកអីវិញទៅ?

ពិនៈ អាហ្នឹងនៅជាប់ស្រុកកំពង់ត្របែក ។

បូលីៈ ត្រពាំងព្រាយកាលពីពូវាយនៅក្នុងដីខ្មែរ ឬនៅក្នុងដីយួនកាលហ្នឹង?

ពិនៈ កាលហ្នឹងយើងកំណត់ថាវានៅព្រំដែន ភូមិខ្មែរថាព្រំដេន គេឲ្យឈ្មោះថាភូមិខ្មែរៗហ្នឹង ប៉ុន្តែវាលូកចូលទៅក្នុងសុទ្ធតែយួននៅ មិនមែនខ្មែរនៅទេ ។

បូលីៈ ហើយខាងយួនមានដែលវាយចូលមកដល់ដីខ្មែរយើងវិញ?

ពិនៈ វាយ និយាយមិនវាយចឹងវាយ ។ វាយលុកមកចឹងទៅ យើងវាយទៅវិញចឹងទៅ វាយទៅវាយមកបើនិយាយរួមទៅ ។

បូលីៈ ពេលហ្នឹងមនុស្សស្លាប់ច្រើនទេ?

ពិនៈ ចំពោះយុទ្ធជនមានស្លាប់ មានរបួសជាប់ជាប្រចាំដែរ មិនដែរអត់ទេពេលនោះ អត់ធម្មតាសមរភូមិ មិនដែលគេចផុតទេ គ្រាន់តែថាវាមិនស្លាប់ទាំងអស់ ស្លាប់មួយសមរភូមិតែ៣ ទៅ៤នាក់អីចឹង ៧,៨នាក់អីចឹងទៅ ។ តាមសមរភូមិតូច សមរភូមិធំចឹងណា ។

បូលីៈ ចុះប្រជាជនពេលដែលយើងវាយចូលទៅដល់ដីយួន ហើយមិនចូលដល់ភូមិយួនហេ៎?

ពិនៈ បាទ!

បូលីៈ ចុះប្រជាជននៅក្នុងភូមិជនជាតិយួននោះ?

ពិនៈ មិនមាននៅទេ! តាយើងវាយចូលវាដករត់បាត់អស់ហើយ ។

បូលីៈ ទាំងកងទ័ព ទាំងប្រជាជនសាមញ្ញ?

ពិនៈ បាទៗ! ហ្នឹងហើយ ។ យើងវាយៗ តែទល់មុខកងទ័ព ប្រជាជនយើងមិនដែលបានជួប ប្រជាជនអាហ្នឹងមិនបានឃើញចំពោះខ្ញុំទេណា មិនដែលបានឃើញប្រជាជនយួន១ផង ។ មានឃើញតែផ្ទះសម្បែង មានតែឃើញតែសម្ភារដូចជា នង្គ័ល រនាស់អីចឹងទៅណា ។

បូលីៈ ពូដែលឃើញថ្នាក់ដឹកនាំធំ ដូចតាសោភឹមតាអីចុះទៅ ជួបចរចាជាមួយដែរទេ?

ពិនៈ កាលហ្នឹង ។

បូលីៈ ដូចអត់បានដល់ហ្នឹងទេ ព្រោះយើងនៅតូច ។ គេមិនឲ្យយើងដឹង មិនដឹងថាទៅចរចា ឬក៏ទៅយ៉ាងម៉េចក៏យើងអត់បានដឹងដែរណា?

ពិនៈ បាទ!

បូលីៈ ពូនៅព្រំដែនហ្នឹងនៅរហូតដល់ឆ្នាំណាពូ?

ពិនៈ ទល់ដែន រហូតដល់ឆ្នាំ៧៨ ។

បូលីៈ ពេលដែល គេចោទសោភឹមថាក្បត់ថាអីពូនៅឯណាកាលហ្នឹង?

ពិនៈ កាលហ្នឹង ខ្ញុំនៅព្រំដែននៅឡើយ ។ កាលហ្នឹង មានសភាពការកើតឡើង វារាងច្របល់ហើយកង់ទ័ព ប៉ុន្តែគ្រាន់តែថា យុទ្ធជនតូចតាចវាអត់សួរអីទេ បញ្ជាមេៗគេ ដែលគេត្រូវហៅទៅអីទៀតបាត់អស់ទៅ ។

ថនៈ ចុះហូយអី បាត់ដែរ ឬក៏?

ពិនៈ បងហូយ?

ថនៈ បាទ!

ពិនៈ បងហូយអត់ទេ! នៅរហូត ។ បងហូយ បងសេម គាត់នៅក្នុងកងពល ។ ឥលូវហ្នឹងនៅជាអាចារ្យវត្តហើយ ប្រពន្ធក៏មិនយកដែរអត់បានជួបផ្ទាល់ទេ ជួបតាមទូរស័ព្ទ សួរសុខទុកតាមទូរស័ព្ទក៏បាត់ទៀត ប្រហែលជាគាត់ដូរក៏មិនដឹង ។

បូលីៈ អាចារ្យវត្តនៅខាងណាវិញ?

ពិនៈ នៅវត្តដង្កោ ស្រុកបរភ្នំ ស្រុកកំណើតគាត់ហ្នឹង ។

បូលីៈ ពេលដែលគេចោទថាសោភឹមក្បត់ ពេលនោះពូមានអារម្មណ៍ថាម៉េច?

ពិនៈ ទេ! កាលហ្នឹង វាមានអារម្មណ៍គិតដែរ មិនមែនថាមិនគិតទេ ។ ចង់និយាយគិតហ្នឹងភារកិច្ចយើងជាយុទ្ធជនហ្នឹង គ្រាន់តែគិតថា បើគេថាមេក្បត់ចុះអស់មេ យើងទៅពឹងអីទៀត នឹកឃើញចឹងណា តែប៉ុណ្ណឹងទេ ដូចមិនមាអារម្មណ៍អីច្រើនទេ ។

បូលីៈ ពូជឿដែរអី ថាសោភឹមគាត់ក្បត់?

ពិនៈ អត់មានជឿថា មានអារម្មណ៍មួយថាចេះដែរ ម៉េចក៏ថាគាត់ទៅជាក្បត់វិញបើគាត់ខំដឹកនាំ ដល់ថ្នាក់ភូមិភាគទៅហើយ ម៉េចក៏ទៅជាក្បត់យើងក៏មានចម្ងល់ចឹងដែរណា! ជាទស្សនមានអារម្មណ៍ចឹងដែរ ។

បូលីៈ ចឹងពូនៅហ្នឹង រហូតដល់ឆ្នាំ៧៨ បន្ទាប់មកបញ្ជូនពូទៅណាទៀត?

ពិនៈ បន្ទាប់មកយួនវាយលុកចូល ឆ្លងទន្លេមេគង្គមកលិចទៅ ហែលឆ្លងទឹកទៅកាប់ដើមចេកហែល ។

បូលីៈ ហែលចាក់យ៉ាងម៉េចពូ ពូអាចជួយបញ្ជាក់ខ្ញុំផង?

ពិនៈ ហែលទន្លេមេគង្គ នៅលើក្បាលកោះកញ្ចឹងហ្នឹង កោះឆ្លងទីហ្នឹងឯងភូមិសាស្រ្តដីរបស់ស្រុកពាមជ ខាងព្រៃវែង ។

ថនៈ ព្រៃវែងអ្នកលឿងនេះ ក្រោមអ្នកលឿងនេះ គាត់ទៅឯស្រុកស្អាង គាត់ទៅយកប្រាសាទនេះឡើងទៅព្រំប្រទល់កំពង់ស្ពឺឱរ៉ាល់នេះណា ។

បូលីៈ ពូមាននៅនេះទេ ពេលដែលវៀតណាមវាយចូលណាពូ?

ពិនៈ បាទ!

បូលីៈ វៀតណាមវាយចូល ព្រៃវែង ពូនៅព្រះស្ដេចនែកពូ?

ពិនៈ ខ្ញុំនៅឈរជើងព្រំប្រទល់ព្រះស្ដេច កំពង់ត្របែក ។

បូលីៈ ពេលវៀតណាមវាយចូល ពូមកនៅម្ដុំនេះ ម្ដុំបឹងត្របែកពូ ពេលហ្នឹងយើងរត់មកណាវិញ?

ពិនៈ រត់មកលិច ។

បូលីៈ រត់មកលិច ។ រត់មកខាងនេះមិនប៉ះទន្លេ?

ពិនៈ បាទ! ទន្លេមេគង្គក្រោម អ្នកលឿង ។

បូលីៈ អ្នកលឿង ។ ដល់ហើយ ពូឆ្លងទន្លេ ឆ្លងមកខាងណា?

ពិនៈ ឆ្លងកាត់មក(ស្ដាប់ពុំបាន) ប្រាសាទ ស្រុកស្អាង ។

បូលីៈ ស្អាង នៅខេត្តកណ្ដាល ។

ពិនៈ ក្រោមកោះធំនេះឯង ។

បូលីៈ ឆ្លងហើយមកខាងនេះទៀត?

ពិនៈ ឆ្លងកាត់ទៅព្រំប្រទល់នែកតាកែវ ហើយកំពង់ស្ពឺហ្នឹងឯង ។

បូលីៈ កំពង់ស្ពឺ មកខាងឱរ៉ាល់ពូ?

ពិនៈ បាទ!

បូលីៈ អ៊ូចឹងមកខាងរោងចក្របេះមក?

ពិនៈ បាទ!

បូលីៈ រោងចក្រពីនេះកាត់មកស្អាង មកតាកែវ កមពង់ស្ពឺ អត់កាត់តាកែវទេពូ?

ពិនៈ ដាយព្រំប្រទល់តាកែវ ខណ្ឌចែកត្រង់ណា ។

បូលីៈ បន្តិច!

ពិនៈ បាទ!

បូលីៈ ចាក់មក កំពង់ស្ពឺ ឱរ៉ាល់នេះ ។

ពិនៈ បាទ!

បូលីៈ ជិះពីឱរ៉ាល់មកណាទៀត ។

ពិនៈ ចេញពីឱរ៉ាល់មកដល់ទីហ្នឹង ចាប់ផ្ដើមបែកបាក់គ្នា ។

បូលីៈ ពេលមកហ្នឹង មកប៉ុន្មាននាក់?

ពិនៈ	កាលមកអន្លង់ភាពមកទាំងមេទាំងកូន បានមកដល់ហ្នឹងបែកបាក់គ្នាអស់ មេដោយមេទៅ កូនទៅដោយកូនទៅ ដល់មកដល់ហ្នឹង ។

បូលីៈ	អត់មានឯកភាពគ្នាទេពេលហ្នឹង?

ពិនៈ	ពេលហ្នឹងបែកគ្នាអស់អ្នកណាទៅណាៗ បែកអន្លង់ភាពត្រឹមហ្នឹងឯង ដល់ហើយចេះតែទៅទៀតទៅ ។

បូលីៈ	ទៅណាវិញ?

ពិនៈ	ខ្ញុំចាប់មកព្រំប្រទល់ជិតប៉ៃលិននេះវិញ ចូលមកព្រំដែន ។

បូលីៈ	ចឹងពូរត់កាត់តាមនេះ តាមពោធិ៍សាត់?

ពិនៈ	បាទ!

បូលីៈ	ស្រុកអីពោធិ៍សាត់?

ពិនៈ	មិនដឹងស្រុកអីទេ កាលហ្នឹង ។

បូលីៈ	វាលវែង ឬក៏ស្រុកភ្នំក្រវាញ?

ពិនៈ	មួយជួរភ្នំក្រវាញ ។

បូលីៈ	មួយជួរភ្នំក្រវាញ! បន្ទាប់ពីពោធិ៍សាត់មកបាត់ដំបង?

ពិនៈ	បាត់ដំបងមក១ជួរដូវ ចេញពីបាត់ដំបងទៅហ្នឹង ។

បូលីៈ	បាត់ដំបងពូមកនៅខាងណា សំឡូត ឬក៏ប៉ៃលិន?

ពិនៈ	អ៊ូ! មកប៉ៃ លិន, ប៉ៃ លិនមកនៅម៉ាឡៃ ។

បូលីៈ	ហ៊ូ! ចឹងរត់តាំងពីនេះមក?

ពិនៈ	ដល់ពេលញហ្នឹងគេប្រុបាច់ចូលអន្លង់ភាព ដល់ដាច់អស់មេអស់កើយចេះធ្វើទៅតាមអន្លង់ភាពផ្សេងៗ ។

ជនៈ	ម៉ាឡៃមកនៅជាមួយ តាចៀម?

ពិនៈ	នៅជាមួយតាចៀម នៅជាមួយនៃក៏តាភាព នៅជាមួយអីហ្នឹងដែរ ។

បូលីៈ	ជាមួយសុខ ភាព?

ពិនៈ	បាទ!

បូលីៈ	បាទ! ចឹងពូចូលកងពលកាលណា?

ពិនៈ	កាលហ្នឹង មកនៅគេចង់និយាយថាមកនៅហ្នឹង គេឲ្យមកនៅកងដឹកជញ្ជូនទេ ។ គេឲ្យយើងកាន់កាំភ្លើង កាន់អីទេ នៅកងដឹកជញ្ជូន របស់កងពល៤៥០ គេបង្កើតនៅព្រំដែនហើយ ។

បូលីៈ ពីពេលដែលពូ រត់ពីព្រះស្តេចនេះរហូតមកដល់ ខាងប៉ៃ លិន ហើយជិះពីមកដល់ ម៉ាឡៃនេះ ចំណាយពេលអស់ប៉ុន្មាន សរុបទៅ?

ពិនៈ ប៉ុន្មានខែទេ យូរដែរហ្នឹង ។

បូលីៈ យូរដែរ?

ពិនៈ បាទ! អត់បាយ អត់ទឹក គ្រុនឈឺសឹងតែស្លាប់នៅហ្នឹង វេទនាណាស់ ។

បូលីៈ ពេលដែលពូមកពីនេះ មកដល់ឌិវ៉ាល់នេះ យើងនៅមានកងមានក្រុម មកដល់នេះបែកគ្នា ។

ពិនៈ និង ហើយបែកត្រឹម ពោធិ៍សាត់ហ្នឹង ។

បូលីៈ ដល់ពោធិ៍សាត់បែកគ្នា?

ពិនៈ បាទ! ដល់ពោធិ៍សាត់ត្រឹមឌិវ៉ាល់ កំពង់ស្ពឺហ្នឹង ។

បូលីៈ ពេលដែលបែកគ្នានឹង ពេលដែលពូរត់ពីពោធិ៍សាត់ហ្នឹង មកដាយដែននេះមានគ្នាប៉ុន្មាននាក់ពូ?

ពិនៈ ខ្ញុំកាលមកហ្នឹង មានគ្នា១០នាក់ជាង មួយជុំគ្នាហ្នឹង ប្រហែលជា១៤ ទៅ១៥នាក់ ។

បូលីៈ អ្នកទាំង អស់នោះសុទ្ធតែជាកងទ័ព?

ពិនៈ សុទ្ធតែកងទ័ពទាំងអស់ ។

បូលីៈ ហើយពេលដែលរត់មកហ្នឹង យើងមានស្បៀងខ្លះជាប់ខ្លួន?

ពិនៈ ទេ! ពីដំបូងយើងមានអាវុធអាអីចឹងតា តែក្រោយមកគេដកទៅ ប៉ុន្តែយើងចេះតែមកទៅណា ហើយជាអន្តភាពបាក់បែកហើយគេមិនទុកចិត្ត និយាយឲ្យខ្លី ។ ហើយដល់ក្រោយបានបញ្ចូល មកអន្តភាព ៤៥០ ។

បូលីៈ ពីណាគេអ្នកដកអាវុធ?

ពិនៈ ដកអាវុធ មិនដឹងពីណាគេទេ ។

បូលីៈ ខាងគេ?

ពិនៈ បាទ! អ្នកនៅកងទ័ពដូចគ្នា ។

បូលីៈ ខ្មែរក្រហមដូចគ្នា?

ពិនៈ បាទ!

បូលីៈ មកហ្នឹង! ការហូបចុកតាមផ្លូវយ៉ាងម៉េចដែរពូ មិនមែនតែ១ថ្ងៃ ២ណា រាប់ខែនោះ?

ពិនៈ អត់ទេ! ការហូបចុកនោះ ហូបគាស់ដំឡូងព្រៃ ដំឡូងអីហូបទៅ ។ ដំឡូងដុះតាមព្រៃ ដំឡូងជ្រៅ ដំឡូងអី ដំឡូងប្រកអីហ្នឹងណា ។

បូលីៈ ហើយដេកយប់ឡើងយ៉ាងម៉េចទៅពូ?

ពិនៈ ដេកយប់អង្រឹង! អាអង្រឹងយើងនីឡុង ដេកតាមដើមឈើ ។

បូលីៈ ដេកអង្រឹងខ្លះទៅ ចងជាមួយដើមឈើពូ?

ពិនៈ បាទ!

បូលីៈ មានកាត់តាមភូមិប្រជាជនទេ ពេលរត់មក?

ពិនៈ រត់! មានកាត់ដែរតា ។ ពេលដែលយើងកាត់ ដូចមានភូមិសាស្ត្រខ្លះ យើងបានកាត់ខ្លះ ពេលខ្លះយើងអត់បានកាត់ ព្រោះយើងខ្លាចដែរកាលហ្នឹង ។

បូលីៈ ពូអត់ចាំថាយើងអត់ចំណាយពេលប្រហែលប៉ុន្មានខែ?

ពិនៈ អត់ៗយើង អត់ ។

បូលីៈ ១ខែ ២ខែ ឬក៏យ៉ាងម៉េច?

ពិនៈ បាទ! អត់ទេ ។

ផនៈ ចុះពេលរដ្ឋពីនោះមក៧៩ហ៎ពូ ឬក៏ចុង៧៨?

ពិនៈ ៧៩ហើយ អាហ្នឹងចូល៧៩ ។

ផនៈ ហើយចឹងឆ្នាំប៉ុន្មានបានទៅដល់ម៉ាឡៃ?

ពិនៈ បើគិតទៅ មុនហ្នឹងទៅដល់ម៉ាឡៃ មុនដំបូងត្រូវនៅអន្លុងភាពនេះទេ ទៅជាយដែនរត់ឆ្ងាយទៅ នៅខាងជើងទេ ដំបូងណា ។

បូលីៈ ខាងណាវិញ?

ពិនៈ រត់ឆ្លងមួយជួរ កាត់អាម្តុំអន្លង់អំពិល ឡើងទៅទន្លេវិញ ។

បូលីៈ នៅក្នុងស្រុកអី?

ពិនៈ ខេត្តបាត់ដំបងវិញ ។

បូលីៈ ស្រុលអីគេ?

ពិនៈ ហ៊ឹម! ទីហ្នឹង មិនដឹងស្រុកអីទេ ខាងកើតតារាងយន្តហោះចាស់ ។

ផនៈ នៅជិតទីរួមខេត្ត?

ពិនៈ ជិតទីរួមខេត្តហ្នឹងដែរ អាហ្នឹងគ្រាន់តែយួនឆ្លងកាត់ទេណា កាត់ភូមិម្តុំហ្នឹង ។

បូលីៈ ហើយបានចាកពីភូមិហ្នឹងនមក?

ពិនៈ ចុះមកទន្លេវិញ ។ ចុះមកទន្លេហ្នឹងមកជួប អន្លុងភាពតាយ៉ែនវិញ ។

បូលីៈ ហ៎ូ! ចុះមកទន្លេសាបវិញ?

ពិនៈ បាទ! ទន្លេសាបវិញ ។

បូលីៈ មិនមែនមកព្រំដែន ចូលទៅក្នុងវិញ?

ពិនៈ បាទ! ចូលទៅក្នុងវិញ ។

បូលីៈ ចូលទៅក្នុងចូលទៅទន្លេសាប, ម៉េចបានលោកពូបត្តូរទិសដៅទៅទន្លេសាប ម៉េចបានមិនមក ព្រំដែន?

ពិនៈ ហ៊ូ! កាលហ្នឹង គេរៀបចំឡូទៅនៅ ចង់និយាយថាគេរៀបចំកម្លាំងទៅជួយដឹងជញ្ជូន ជួយវាយនៅតាមផ្លូវជាតិ អាម៉ុំវាលស្រែ អាម៉ុំអីអន្លង់វិលហ្នឹង ។ ដល់ពេលរថក្រោះមកវាទៅមិនកើត រត់ទម្លាយផ្លូវមកទៅដើងវិញទៅ ។

បូលីៈ ទម្លាយផ្លូវជាតិលេខ៥?

ពិនៈ បាទ!

បូលីៈ ផ្លូវជាតិលេខ៥ ឬលេខ៦?

ពិនៈ ផ្លូវជាត់លេខ៥នេះ ។

បូលីៈ ទម្លាយផ្លូវនេះមកព្រំដែន ។

ពិនៈ មកចុះទន្លេ ចុះទន្លេសាបបានមកជួប ហង្ស សុភាព ខាងតាយ៉ន ទៀត ។

បូលីៈ តាយ៉ន ពីណាគេ?

ពិនៈ តាយ៉ន មេកងពល ដូចពីមុនគាត់កងពល៥១៩ ច្រើនណាស់ជូរចត់ណាស់ខ្ញុំ ជីវិតខ្ញុំ ទីណាត់ទីណែង ប៉ុនចេះអត់ស្លាប់ដែរ ។

បូលីៈ ខ្ញុំអត់ដឹងច្បាស់ពេលដែលពូរត់ពីព្រៃវែងមក ពូមកដល់ជាយដែនសិន បានគេប្រជុំបកមកធ្វើការនៅទន្លេសាប?

ពិនៈ អត់ទេ! អត់ដល់ព្រំដែនទេ ។ មកដល់ត្រឹមតែផ្លូវជាតិលេខ១០ហ្នឹងបានគេបញ្ជូនឡើងមក គេចាប់បញ្ចូលអង្គភាពដូចខ្ញុំថាអីចឹង ប្រធានអង្គភាពមកនៅជួយនាំអង្គភាពនៅផ្លូវជាតិលេខ៥ ។

បូលីៈ មកវាយនៅផ្លូវជាតិលេខ៥នេះ?

ពិនៈ បានមកឆ្លងផ្លូវ ទៅនៅទន្លេសាប នៅទន្លេសាប១គន្លាក់ទៀត ។

បូលីៈ នៅ១គន្លាក់ទៀតហើយ ។

ពិនៈ បាទ! រត់បាក់បែកគ្នាទៀតហើយ ធម្មតាចាញ់គេមិនរត់ខ្ចាត់ខ្ចាយ ។

បូលីៈ នៅទន្លេសាបនេះនៅបានប៉ុន្មាន?

ពិនៈ ទេរត់ទៅទន្លេសាប ប្រហែលជា៣ ទៅ៤ថ្ងៃជួបអង្គភាព៥១៩ ខាងតាយ៉ន ខាងអង្គភាព!

បូលីៈ អាហ្នឹងខាងជើងអូរជ្រៅ?

ពិនៈ បាទ! ខាងជើងអូរជ្រៅ ។

ជនៈ ខាងជើងអូរជ្រៅ?

ពិនៈ បាទ!

ថន៖ ខាងជើងអូរជ្រៅ១៩ ដល់ពេលមកខាងត្បូងនេះមកម៉ាឡៃនេះ៤៥០?

ពិន៖ បាទ!

បូលី៖ ខាងអូរជ្រៅពីនេះ៥១៩?

ពិន៖ បាទ!

ថន៖ បើខាងផ្លូវជាតិបុកទៅ ប៉ោយប៉ែត?

ពិន៖ បាទ! បុកទៅ ប៉ោយប៉ែតវិញ ។

បូលី៖ ដល់ពេល៤៥០ គេវាយពីអូរជ្រៅមកខាងម៉ាឡៃវិញ?

ពិន៖ បាទ!

បូលី៖ ចឹងពូនៅក្នុងកងពលលេខប៉ុន្មាន?

ពិន៖ កាលហ្នឹងមក ដល់មកហ្នឹងនៅ១៩ហ្នឹង មុនដំបូងអត់ធ្វើអីទេ មកនៅធម្មតាតាមជំរុំជនភៀស ខ្លួន រត់ចូលភៀសខ្លួន ។

បូលី៖ ចឹងបានន័យថាពូមិនមែននៅក្នុងកង៤៥០របស់សុខភាពទេចឹង?

ពិន៖ អត់ទេ! គ្រាន់តែក្រោយ ក្រោយបានទៅដឹកជញ្ជូន ។

បូលី៖ មកក្រោយបានមកដឹកជញ្ជូនកងពល៤៥០?

ពិន៖ ហ្នឹងហើយ ។

បូលី៖ តែដំបូង ស្ថិតនៅក្រោយមការគ្រប់ខណ្ឌ៥១៩ ។

ពិន៖ ទៅនៅតាមជំរុំ?

បូលី៖ ជំរុំអីខ្លះកាលហ្នឹង?

ពិន៖ កាលហ្នឹងទៅនៅចម្ការគ កាលហ្នឹងគេបង្កើតជំរុំហេយកាលហ្នឹង ដល់ឆ្នាំ៨០ ។

បូលី៖ ជំរុំចម្ការគ?

ពិន៖ បាទ!

បូលី៖ ចម្ការគ របស់ខាងខ្មែរក្រហម ឬក៏របស់?

ពិន៖ របស់ខ្មែរក្រហម ។

បូលី៖ មិនមែនរបស់ UN ទេ?

ពិន៖ របស់ខ្មែរក្រហមគ្រប់គ្រង ។

បូលី៖ ចម្ការគ បើយើងនិយាយទៅ នៅក្នុងដីថៃ ឬក៏ដីខ្មែរ?

ពិន៖ ដីខ្មែរវិញ?

បូលី៖ បាទ! ដីខ្មែរ ។ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកអី?

ពិនៈ ទីហ្នឹងដូចស្រុកស្វាយចេកហ្នឹង ។

ផនៈ ភូមិស្វាយចេក?

ពិនៈ បាទ! ស្វាយចេកហ្នឹងឯង ចុះវាឆ្លងកាត់បឹងស្នោរ ស្លក្រាម ស្លអីហ្នឹង ស្វាយចេកហើយទីហ្នឹង ។

បូលីៈ ស្វាយចេក?

ពិនៈ បាទ!

បូលីៈ ចុះភ្នំឆ័ត្រនៅណាពូ?

ពិនៈ ភ្នំឆ័ត្រ នៅជើងចម្ការគេវិញ ។

បូលីៈ ខាងជើងចម្ការគេវិញទៀត ។ ពេលដែលពូនៅ៩១៩ហ្នឹង គេចាត់តាំងពូឲ្យមកខាងទន្លេសាបទៀតអត់ទេ?

ពិនៈ ខ្ញុំអត់ដែលបានមកទេ ។

បូលីៈ លែងចុះមកទៀតហើយ?

ពិនៈ បាទ! ទៅនៅជំរុំវិញ ។

បូលីៈ នៅធ្វើអីតាមជំរុំ?

ពិនៈ នៅជំរុំបានគេជួយនោះ ។

បូលីៈ ជំនួយពីណាមក?

ពិនៈ អង្គការនោះជំនួយពីអង្គការសហប្រជាជាតិហ្នឹង ពីណាមិនដឹងជំនួយ ។ កាលហ្នឹងតាមរយៈថៃអ្នកដឹក ហើយមានពួកបរទេស ដូចមានពួកបារាំងពួកអីចឹងណា ។

បូលីៈ ពូមានដឹងថានៅខាងម៉ាឡៃនេះមេធំ គ្រប់គ្រងពីណាគេទេ?

ពិនៈ នៅម៉ាឡៃ?

បូលីៈ មេខ្មែរក្រហមធំណា?

ពិនៈ នៅម៉ាឡៃ មេខ្មែរក្រហមធំ មានតែអៀង សារីហ្នឹង គាត់នៅហ្នឹងជាប់ ។

បូលីៈ តាអៀងសារី គាត់គ្រប់គ្រងនៅហ្នឹង បន្ទាប់ពីអៀងសារីមកពីណាទៀត?

ពិនៈ មានតែតាហុង មានតែតាអីហ្នឹង កងពលមានតាភាព មានអី ។

បូលីៈ កងពលមានតាភាពណ៎?

ពិនៈ បាទៗ! សុខភាព ។

បូលីៈ សុខភាព ហើយកងពល៩១៩ តាយ៉ន?

ពិនៈ ដំបូងតាយ៉ន ដល់ក្រោយមក បងសារឿនវិញ ។

បូលី៖ អីសារឿន?

ពិន៖ ដុល សារឿន ។

បូលី៖ ដុលសារឿន ។ តាយ៉ន អីយ៉នពូ ត្រកូលគាត់?

ពិន៖ មិនដឹងជាស្អីយ៉នទេ ត្រកូលភ្លេចបាត់ហើយ ។

បូលី៖ តាយ៉ន, តាដុល សារឿន, ចុះតា ប៉ុនស្ទួអី?

ពិន៖ តាស្ទួ គាត់នៅកោះឈូប ស្រុកស្វាយចេក គេឲ្យគាត់ធ្វើសកម្មភាពនៅហ្នឹង ។

បូលី៖ នៅស្វាយចេកណ៎?

ពិន៖ បាទ! ពីណាគេទៅថ្មពួក? ហ៉ើកាលហ្នឹងនៅអង្គភាពណាទេ ទៅថ្មពួកនោះ ទាំងអង្គភាពផែក វរៈណាទៅហ្នឹង ។

បូលី៖ ស៊ីសាផុន ពីណាគេ?

ពិន៖ សីសាផុនខាងត្បូង ភាពហ្នឹងឯង បញ្ញា ។ ខាងជើង បងសារឿនហ្នឹងឯងបញ្ញា ។

បូលី៖ ចុះពីណាគេចុះមកធ្វើការ ខាងបាត់ដំបង?

ពិន៖ ខាងបាត់ដំបងមាន តាមវរៈគេ តាមវរៈ មាន៣៣០ មាន៤៥០ អីចឹងទៅណា ។

បូលី៖ ចឹងបាន ន័យថាកងពល៥១៩ និង៤៥០នេះទទួលខុសត្រូវអើខេត្ត២បាត់ដំបង១ បន្ទាយមានជ័យ១?

ពិន៖ បាទ! ខាងជើងផ្លូវ និងខាងត្បូងផ្លូវ ។

បូលី៖ ចង់និយាយថាផ្លូវជាតិលេខ៥ហើយនេះ?

ពិន៖ បាទ! ផ្លូវជាតិលេខ៥ ។

ថន៖ បុកទៅប៉ោយប៉ែត ។

បូលី៖ បាទខាងជើង ខាងត្បូង ។

ពិន៖ ហ្នឹងហើយ ខាងជើង ខាងតាបងសារឿនហ្នឹង ។

បូលី៖ ខាងណាខាងជើង ខាងណាខាងត្បូងបើយើងមើលតាមផែនទី? នេះលេខ៥ នេះ!

ពិន៖ បាទ! នៅម្ខាងផ្លូវម្នាក់ ។

បូលី៖ ម្ខាងផ្លូវម្នាក់!

ពិន៖ បាទ!

បូលី៖ ខាងនេះផ្លូវពីណាគេ?

ពិន៖ តាភាព ។

បូលី៖ ខាងនេះផ្លូវ តាសុខភាពណ៎?

ពិនៈ បាទ!

បូលីៈ ៤៥០?

ពិនៈ ខាងនេះផ្លូវ៥១៤?

បូលីៈ ខាងបងសារឿន! តា ដុល សារឿន។ ផ្លូវមានពីរ ផ្លូវជាតិលេខ៥ និងលេខ៦ យើងឡើងផ្លូវជាតិលេខ៦យើងអត់គិតទេ?

ពិនៈ ផ្លូវជាតិលេខ៦ យើងកុំចូលផ្លូវជាតិលេខ៥វិញ។ វាអត់មានលាតសន្ធឹង ទៅផ្លូវជាតិលេខ៥ឆ្ងាយទៅប៉ោយប៉ែត។

បូលីៈ ចឹងយើងយកផ្លូវជាតិលេខ៥ ធ្វើជាព្រំដែនបែងចែកខណ្ឌគ្នា?

ពិនៈ បែកចែកខណ្ឌ។

បូលីៈ ១ចំហៀង ផ្លូវជាតិលេខ៥ តាំងពីបាត់ដំបងរហូតមកដល់អូរជ្រៅប៉ោយប៉ែតនេះ និងតាសុខភាព។

ពិនៈ នៅខាងជងផ្លូវ។

បូលីៈ ហើយនេះត្បូងនេះពូ?

ពិនៈ បាទ!

បូលីៈ នេះជើង?

ពិនៈ បាទ!

បូលីៈ យល់ទេពូ?

ពិនៈ បាទ!

បូលីៈ ខ្ញុំអាចស្វែងយល់បានខ្លះ។ ៥១៩ខាងនេះ ៤៥០ខាងនេះ។ ប៉ុន្តែខាងប៉ៃលិន កាលហ្នឹងដូចជាមិនទាន់មានជាខេត្តទេណាពូ?

ពិនៈ បាទៗ! នៅជាបាត់ដំបងនៅឡើយទេ។

បូលីៈ ពូមានដឹងទេថាកងពលណាទទួលខុសត្រូវខាងប៉ៃលិន?

ពិនៈ ប៉ៃ លិន។ ប៉ៃ លិន មានតែតាឈាន ហ្នឹងឯង។

បូលីៈ អ៊ី ឈាន?

ពិនៈ បាទ!

បូលីៈ អ៊ី ឈាន ហ្នឹងកងពល១?

ពិនៈ បាទ! អ៊ី ឈាន។ មិនដឹងកងលេខប៉ុន្មានទេ ខ្ញុំអត់សូវចាំដែរ។ ខាងនេះមានច្រើនកងពលដែរគ្រាន់តែតាមដឹង វាមានកងពលខាងដូជ៣២០របស់តាសុក របស់អីណា។

បូលី៖ នី កនអី?

ពិន៖ បាទ! របស់តាកនអី ។

បូលី៖ តាកន?

ពិន៖ បាទ! ហើយបន្ទាប់ទៅ បានទៅនៅខាងតាឈាន ទៅខាងតាបិតទៅនៅខាងត្បូងនោះទៀត ។

បូលី៖ សំ បិត គាត់នៅក្នុងកងពលលេខប៉ុន្មាន?

ពិន៖ ទេ! គាត់ដូចជានៅក្នុងកងពលលេខប៉ុន្មានទេនេះ? ខ្ញុំអត់ចាំដែលណា ដល់តែខាងលើពេកលែងចាំ ចាំតែអង្គភាពខ្លួនឯង ។

បូលី៖ ព្រោះតាមខ្ញុំដឹង គេវាចែក២ធំៗ ។ តំបន់ម៉ាឡៃ គេចែកជាសមរភូមិទិសមួយ ហើយសំពៅលូននេះរបស់តានី កន នេះជាសមរភូមិទិសមួយ ។ ខ្ញុំចង់ដឹងថាតើ ខាងនី កនវាយទៅខាងណាខ្លះខាង៣២០ណា ។ កាលនោះពូមានដឹងទេកាលហ្នឹង?

ពិន៖ ខាងតាកន អាចវាយចុះមកនេះឯង បើភ្ជាប់ជាមួយតាភាព ខាងតាកនអាចវាយចូលអាម៉ុផ្លូវជាតិលេខ១០នោះឯង ។ ច្បាស់អាម៉ុចុងហ្នឹងឯង ។

បូលី៖ ផ្លូវជាតិលេខ១០នៅម៉ុណាវិញ?

ពិន៖ ពីបាត់ដំបងទៅដែរ ។

បូលី៖ ទៅណាវិញ?

ពិន៖ ទៅប៉ៃ លិន ។

បូលី៖ ពីបាត់ដំបងមកប៉ៃ លិន?

ពិន៖ បាទ!

បូលី៖ ចឹងផ្លូវ៥៧?

ពិន៖ បាទ!

បូលី៖ ចឹង! ខាង នី កន ខាង៥៧?

ពិន៖ បាទ! អាចវាយភ្ជាប់គ្នាខាងតាភាព ជាមួយដែលខាងតាឈាន នេះណា អាចចន្លោះនេះឯងអានេះតាមខ្ញុំយល់ទេ ។

ផន៖ មិនទទួលខាងបវិល ខាងភ្នំព្រឹក្សអីទេ?

ពិន៖ បាទ! អាចទទួលខាងហ្នឹងឯង ។ ខាងគាត់ទទួលនៅហ្នឹង ខាងគាត់ទទួលខាងហ្នឹង ខាងបវិលភ្នំព្រឹក្សហ្នឹង ។

បូលី៖ សំពៅលូន, ភ្នំព្រឹក្ស, កំរៀង យើងច្បាស់ហើយថានី កន អ្នកទទួលណា ។

ពិន៖ បាទ!

បូលី៖ ប៉ុនខាងនី កន ហ្នឹង គាត់អាចកងពល៣២០, ៧០៥, ៩៨៨នេះណា៎ គាត់អាចវាយចូលដល់ផ្លូវជាតិលេខ៥តាមមើល?

ពិន៖ អាច! អាចដល់ៗ តាមមើលទៅ ផងចសហការគ្នាណា ព្រោះកងទ័ព អាហ្នឹងគេត្រូវការ គេសហការអង្គភាព១ ទៅអង្គភាពមួយៗ

បូលី៖ សហការជាមួយតាភាព?

ពិន៖ បាទ!

បូលី៖ នេះខាងនេះមានសមរភូមិទិសលេខ១៨ណា៎ៗ

ពិន៖ បាទ!

បូលី៖ មានតាមាស មុត, នៅខាងកោះកុងៗ

ពិន៖ តាមុត គាត់ទើបតែទៅហ្នឹងក្រោយដែរតា កាលមុនគាត់នៅនេះដែរតាៗ

បូលី៖ គាត់នៅ១០០១?

ពិន៖ បាទ! ដូរមកនៅខាងនេះៗ

បូលី៖ មានតាម៉េតៗ តាម៉េត នៅខាងណា៎ពូដឹងទេ?

ពិន៖ តាម៉េត គាត់ទៅនៅខាងណាទេនេះ ខ្ញុំអត់ដឹងដែរ គាត់ខាងលើចឹង ខ្ញុំមិនសូវដឹងដែរៗ

បូលី៖ អានេះគេចូលមកធ្វើការមកខាងក្នុងវិញណាពូ?

ពិន៖ បាទ!

បូលី៖ គេមានទីតាំងធំៗ ១០០១, ១០០៣, ផាយមកនេះមានម៉ាឡៃ, ម៉ាឡៃ ហើយសំពៅលូន ហើយហ្នឹងខាងកោះកុង ពោធិ៍សាត់ ចឹងពូ ពូនៅក្នុងជំរុំដែរទេ?

ពិន៖ បាទ! ពេលក្រោយបានគេលែងឲ្យនៅៗ

បូលី៖ នៅដល់ពេលណាបានគេលែងឲ្យនៅ?

ពិន៖ ខ្ញុំនៅឆ្នាំ៨០ ដល់មកឆ្នាំ៨៣បែកជំរុំ៨៣ហ្នឹង ក៏រត់ទៅនៅជំរុំក្រង៉ុកទៀត ក្រង៉ុកនៅខាងប្រកម៉ាឡៃនោះណា នៅព្រំដែនខ្ទុចខ្ទីអស់ វាយកាលហ្នឹងវាយពី៨៣ៗ

បូលី៖ ៨៣,៨៤?

ពិន៖ បាទ!

បូលី៖ ដែលថាវៀតណាមធ្វើប្រតិបត្តិការ បោសសម្អាតព្រំដែនហ្នឹងហើយ?

ពិន៖ បាទ! ហ្នឹងហើយ, ៨៣,៨៤ៗ

បូលី៖ ពេលបែកហ្នឹង បែកយ៉ាងម៉េចពូ?

ពិនៈ ប្រពន្ធកូនរបស់កងទ័ពទាំងអស់ត្រូវរត់ទៅតាមជំរុំទាំងអស់កាលហ្នឹងណា ។ ហើយបានគេយកចេញពីជំរុំទៅនៅតាមអង្គភាពវិញ ពង្រឹងតាមអង្គភាពវិញ ។

បូលីៈ ប៉ុនពូចង់មានន័យថា តាមជំរុំទាំងអស់ហ្នឹង គឺនៅក្នុងដីថៃ ឬដីខ្មែរ?

ពិនៈ ជំរុំ!

បូលីៈ បានន័យថាដីខ្មែរយើង គឺអស់ទីតាំងឈរជើងហើយ?

ពិនៈ បាទ!

បូលីៈ យួនវាយយកទាំងអស់ ។

ពិនៈ បាទ! យួនវាយយកហើយ ។

បូលីៈ ពេលហ្នឹងពូមកជំរុំក្រង៉ុកវិញ?

ពិនៈ បាទ! ទៅរកង៉ុកវិញ ។

បូលីៈ ប៉ុនពូនៅក្មេងដែរ ហើយជាយុវជនពេញកម្លាំងទៀតក៏គេទុកឲ្យនៅជំរុំចឹង?

ពិនៈ ចុះយើងចេះតែគេច គេចទៅ ។

បូលីៈ គេអត់បញ្ជូនឲ្យមកធ្វើការខាងក្នុងទេណ៎?

ពិនៈ ដល់ក្រោយបានគេចមិនផុត ដល់ឆ្នាំចូល៨៨វិញ គេត្រូវរុញមកវិញហើយ ។

បូលីៈ ឆ្នាំ៨៨ គេបញ្ជូនចូលមកវិញ?

ពិនៈ បាទ!

បូលីៈ ប៉ុនពេលដែលពូមកនៅក្រង៉ុកហ្នឹង ពូនៅក្នុងអង្គភាព៥១៩ដែរ ឬក៏ដូរ?

ពិនៈ អ៊ូ! នៅក្នុង៥១៩ ដដែរតា ។

បូលីៈ ដដែរទេ? ធ្វើអីពូ នៅម្តុំក្រង៉ុក?

ពិនៈ ទៅនៅខាងនោះ ទៅនៅប្រជាពលរដ្ឋធម្មតា ប្រជាជនធម្មតា ទៅនៅប្រពន្ធ បើកអង្កទៅ ។

បូលីៈ របបគេមានអីខ្លះក្រៅពីអង្ករពូ?

ពិនៈ អង្ករ, ត្រីខ, ត្រីកំប៉ុង, ខ្លាញ់អីហ្នឹង ហូប១អាទិត្យម្តង កាលហ្នឹង ។

បូលីៈ ១អាទិត្យ បើកម្តង?

ពិនៈ បាទ! ១អាទិត្យបើម្តងតាម Unicef ហ្នឹង ។

បូលីៈ អ៊ូ! Unicef ហេ៎?

ពិនៈ បាទ! មកជួយមក ។

បូលីៈ ប្រហែលជាមានមនុស្សប៉ុន្មាននាក់នៅក្រង៉ុកហ្នឹង?

ពិនៈ អីយ៉ាច្រើនៗ អង្គភាព កាលហ្នឹងមាន ទាំងអង្គភាពបែកខាងត្បូង ទាំងអង្គភាពបែកខាងជើង ហ្នឹង គេបកទៅនៅជិតរំពប់ម៉ឺនណា! ប្រហែលជា២ ទៅ៣ម៉ឺនហ្នឹង ច្រើនណាស់ មនុស្សច្រើនណាស់ ច្រើនមែនទែនៗ

បូលីៈ ហើយការរស់នៅដូចថាយើង យើងនៅផ្តុំគ្នាជាជំរុំធំមួយចឹង ឬក៏យើងនៅតាមអង្គភាពតូចៗចេះ?

ពិនៈ ទៅដល់ហ្នឹងគេអ្នកចែក មិនមែននៅលើយើងអ្នកចែកទេ លើខាងអង្គការសហប្រជាជាតិ គេចែកជាឡូ ជាសង្កាត់ចឹងណាៗ ចែកជាសង្កាត់ ចែកជាឡូចឹងទៅក៏យើងទៅនៅតាមសង្កាត់ តាមឡូណាចឹង ឈ្មោះយើងមានបញ្ជីឈ្មោះចឹងទៅណាៗ

បូលីៈ ហើយផ្ទះសម្បែងអីពីណាធ្វើឲ្យនៅ?

ពិនៈ ហ៊ូ! ផ្ទះសម្បែងគេដឹកឫស្សី ដឹកស្លឹក ដឹកអីយកទៅឲ្យយើងធ្វើខ្លួនយើងៗ ធ្វើផ្ទះតូចៗ ជាប់ៗគ្នាៗ

បូលីៈ ពេលនោះពូមានប្រពន្ធរួចហើយ?

ពិនៈ មានហើយ!

បូលីៈ ពូការនៅម្តុំណា?

ពិនៈ នៅចម្ការគយនេះៗ

បូលីៈ នៅចម្ការគយ?

ពិនៈ បាទ!

បូលីៈ នៅខាងម៉ាឡៃ?

ពិនៈ ខាង៨០ ដែលរត់ទៅដល់ព្រំដែនៗ

បូលីៈ ម៉េចបានពូរកឃើញវិញ?

ពិនៈ កាលហ្នឹងនៅអង្គភាព គាត់ក៏នៅអង្គភាពផ្សេង ខ្ញុំក៏នៅអង្គភាពទៅ មេៗចេះតែផ្គូរផ្គងទៅ កាលហ្នឹងយើង ការក៏យើងគ្មាន ដូចគេក្មេងឥលូវមានភ្លេងអីស្រស់ស្រួលបួល គ្រាន់តែគេរៀបចំផ្តុំផ្សំហ្នឹង ហើយមានការទទួលខុសត្រូវចាប់អារម្មណ៍ ព្រមទទួលគ្នាចឹងទៅណាៗ ជាគ្រួសារចឹងទៅៗ

បូលីៈ ពូពេញចិត្តទេ ពេលហ្នឹង?

ពិនៈ ចុះមានទៅអី មានទៅទាស់ខុសអី?

បូលីៈ មិនមែនគេចេះតែចាប់ផ្ទឹមភ្លល់?

ពិនៈ បាទ! គ្មានអីទេ យើងចេះតែព្រមព្រៀងទៅណា បើតម្រូវមកស្រលាញ់ យើងក៏ពេញចិត្ត ទៅក៏ទៅតាមហ្នឹងទៅ ។

បូលីៈ ពេលដែលពូការហ្នឹង ប៉ុន្មានគូ?

ពិនៈ ខ្ញុំហេ៎?

បូលីៈ បាទ!

ពិនៈ កាលហ្នឹងមេឌ្ឍិផ្សំឲ្យតែ១គូទេ នរណាស្រលាញ់គ្នា មេឌ្ឍិផ្សំឲ្យចឹងទៅណាក្នុងឆ្នាំ៨០ហ្នឹង ។ មិនច្រើនគូដូចគេឆ្នាំ ៧៥,៧៦,៧៧,៧៨ អីទេ វាខុសគ្នា ។ មកដល់ជាយដែន ថាស្រលាញ់ មេ នឹកឃើញចឹងទៅក៏ រៀបចំឲ្យទៅ ។

បូលីៈ ហើយពេលការហ្នឹង យើងមានពិធីប្រពៃណីខ្លះទេកាលហ្នឹងពូ?

ពិនៈ ដូចមិនមានពិធីអីច្រើនទេ! ពិធីគ្រាន់តែជួបជុំគ្នាមេៗ ជួបជុំគ្នាចឹងទៅណា ហើយយើងក៏មាន ការទទួលខុសត្រូវ ចង់និយាយខុសត្រូវថា ប្ដេជ្ញាចិត្តថាយើងរក្សាជាប្ដីជាប្រពន្ធអស់មួយជីវិត ទៅប៉ុណ្ណឹងទេ ដូចមិនមានអីច្រើនផង មេគេណែនាំយើងទៅណា ។

បូលីៈ មេកាលហ្នឹងពីណាគេ?

ពិនៈ កាលហ្នឹង ។ កាលហ្នឹងបងនេះវិញ បងជន់វិញ ប្រធានទៅជំរុំវិញ ។

បូលីៈ ហ៊ូ! មេជំរុំបងនេះវិញ?

ពិនៈ មេជំរុំ!

បូលីៈ ឈ្មោះជន់?

ពិនៈ បាទ!

បូលីៈ ចម្ការគ?

ពិនៈ ចម្ការគ ។

បូលីៈ ឈ្មោះពេញ គាត់ឈ្មោះអី?

ពិនៈ ហេ៎ ឈ្មោះគាត់ហ្នឹង បងជន់តែម្ដង ឈ្មោះគាត់ឈ្មោះពេញតែម្ដង ប្រធានជំរុំចម្ការគតែម្ដង ហើយគាត់យ៉នហ្នឹង មេកងពលហ្នឹង ។ ប៉ុន្តែឥលូវហ្នឹង មិនដឹងទៅណាទេស្លាប់បាត់ហើយ ចាស់ ហើយ កាលនោះគាត់ចាស់ហើយ ។

បូលីៈ ជំរុំនៅចម្ការគ នៅខាងម៉ាឡៃ ឬក៏?

ពិនៈ អត់ទេ! ខាងភ្នំស្រុកនេះវិញ ។

បូលីៈ ស្វាយចេកវិញ?

ពិនៈ បាទ!

បូលីៈ បើជំរុំក្រង៉ុកនៅខាងម៉ាឡៃវិញ?

ពិនៈ នៅខាងម៉ាឡៃ តែពេលក្រោយអ្នកនៅចម្ការគ គេដឹកទៅក្រង៉ុកនោះ ពេលព្រំដែនខ្វាត់ខ្វាយណា ទាំងខ្ញុំទាំងគេហ្នឹង ។

បូលីៈ នៅខាងម៉ាឡៃ នៅខាងដីខ្មែរ ឬក៏ដីថៃ?

ពិនៈ ក្រង៉ុក ដីថៃដែរ គេហៅជំរុំលេខ៨ ។

បូលីៈ ជំរុំលេខ៨ហ្នឹងហ៎ពូ?

ពិនៈ បាទ!

បូលីៈ យល់ហើយ! ម៉េចបានមានឈ្មោះជំរុំឈ្មោះក្រង៉ុកចឹង?

ពិនៈ អាហ្នឹងគេហៅថាភ្នំក្រង៉ុកៗ នៅខាងកើតជំរុំហ្នឹង មិនដឹងវាជាប់ឈ្មោះតាំងពីត្រឹមណាមកយើងវាអត់ដឹងដែរ ។

បូលីៈ សាយអេក ។

ពិនៈ ហ្នឹងហើយសាយអេក, លេខ៨ហ្នឹង ។

បូលីៈ សាយអេក, សាយធូរ,សាយប៊ី ។

ពិនៈ គេបង្កើតតាមព្រំដេនហ្នឹង ធំៗ ។

បូលីៈ សាយអេកហ្នឹងធំណាស់ ។

ពិនៈ ធំណាស់ ។

បូលីៈ អាហ្នឹងបានក្លាយជាជំរុំដែលធំជាងគេបំផុតនៅក្នុងចំនោមតាមព្រំដែនទាំងអស់?

ពិនៈ បាទ! ច្រើនជាងគេ ។

បូលីៈ ព្រោះពេលហ្នឹង ជំរុំរបស់ខ្មែរក្រហមទាំងអស់ប្រមូលគ្នាមកសាយអេកទាំងអស់ ពេលដែលវៀតណាមវាយចូលមក ។

ពិនៈ បាទ! ហ្នឹងហើយ ។

បូលីៈ ដកល់ពូ និយាយថាជំរុំលេខ៨ បានចាប់អារម្មណ៍ ។ ខ្មែរយើងហៅថាជំរុំក្រង៉ុកហ្នឹងហ៎?

ពិនៈ បាទ! ជំរុំក្រង៉ុក ។

បូលីៈ ប៉ុនជំរុំធំមួយទៀតរបស់តាសឺន សាន ។ អើ! រិទ្ធិសែន រិទ្ធអីហ្នឹង ។

ពិនៈ បាទ! រិទ្ធិសែនជាប់ចម្ការគតា ។

បូលីៈ ជាប់ចម្ការគដែរ ។

ពិនៈ អាហ្នឹងនៅក្នុងបន្ទាប់ព្រំដែនខ្មែរដែរអាហ្នឹង ជំរុំដោយឡែក មានជំរុំព្រំដែន តាមដែលខ្ញុំទៅហ្នឹងដឹង វាមានឫស្សីស្រុក ជំរុំរបស់ព្រះអង្គម្ចាស់នរោត្តមរណរិទ្ធហ្នឹង កាលហ្នឹង ហើយដល់មកជំរុំតាសឺន

សាន បានមកជំរុំនៃកដងច័ន្ទហ្នឹងជំរុំថ្មី ដល់បុស្សរីស្រុកខាងព្រះអង្គម្ចាស់ ដល់មកចម្ការគ ភ្នំឆ័ត្រ អាហ្នឹង ជំរុំរបស់ខ្មែរក្រហម និយាយតែម្ដង ។

បូលីៈ ស្រួលស្ដាប់ ។ ហើយពូថាឆ្នាំ៨៤ គេបញ្ជូនពូចុះមិវិញហេ៎ ពេលការហើយ៨០ណា៎?

ពិនៈ បាទ!

បូលីៈ ពេលវៀតណាមវាយបែក?

ពិនៈ បាទ! ៨៤បានគេត្រូវរីតបន្តឹងឲ្យយើងចូលទៅអង្គភាពវិញ បានគេដឹកខ្ញុំចេញពីក្រង៉ុកវិញ ។

បូលីៈ បានន័យថារើសមនុស្សចេញពីជំរុំមកវិញ?

ពិនៈ បាទ! ហ្នឹងហើយ ។

បូលីៈ ពូមានសិទ្ធជំទាស់ទេ?

ពិនៈ អត់មានទេ! គ្មានសិទ្ធជំទាស់ទេ ។

បូលីៈ តែខ្ញុំអត់ចងទៅ ខ្ញុំចង់នៅជំរុំ ។

ពិនៈ (សើច) កាលហ្នឹងគេចង់និយាយថា យើងនៅក្នុងគេចង់ស្រាយវជ្រាវ យើងធ្លាប់ធ្វើកងទ័ព ចឹងគេឲ្យយើងទៅក្នុងអង្គភាពកងទ័ពវិញទៅណា ។

បូលីៈ ពីណាគេអ្នកស្រាវជ្រាវ,

ពិនៈ មានខាងលើ មេដឹកនាំខាងលើៗ ។

បូលីៈ ខាងលើខ្មែរក្រហម ឬខ្មែរជំរុំ?

ពិនៈ ខាងមេជំរុំហ្នឹង គេស្រាវជ្រាវដែរ ។ ខាងមេជំរុំគេស្រាវជ្រាវ ដូចខាងតាសុខ ខាងអីគាត់ស្រាវជ្រាវ គាត់ដឹងនរណានៅឯណា នរណាអង្គភាពណាអាចធ្វើអីចឹងទៅអង្គភាពវិញទៅចឹងណា គេហៅណែនាំយើងទៅណា ។

បូលីៈ ជំរុំហ្នឹង ស្ថិតក្រោមការគ្រប់គ្រងខ្មែរក្រហម ឬក៏របស់?

ពិនៈ របស់ខ្មែរក្រហម សាយអេក ។

បូលីៈ មិនមែនអង្គការសហប្រជាជាតិទេ?

ពិនៈ អង្គការសហប្រជាជាតិគឺ គ្រប់គ្រងស្បៀងគ្រប់គ្រងអី ប៉ុនគ្រប់គ្រងផ្ទាល់ហ្នឹង មេជំរុំខាងខ្មែរក្រហម តាសុក ខាងអីហ្នឹង ។

បូលីៈ បានន័យថាគ្រប់គ្រងមនុស្សជំរុំ គឺខ្មែរក្រហម?

ពិនៈ បាទ!

បូលីៈ ស្បៀងអាហារ គឺអង្គការសហប្រជាជាតិអ្នកផ្ដល់ឲ្យ?

ពិនៈ សហប្រជាជាតិអកផ្តល់ឲ្យ ប៉ុន្តែមិនមានសិទ្ធនិយាយថាមិនឲ្យប្រជាជនមកវាយ ខាងក្នុងទេ ខាងអង្គការសហប្រជាជាតិណា?

បូលីៈ បាទ! គេមានសិទ្ធទេ?

ពិនៈ ទេ! គេមិនដែលពុចឹងផង គិតតែពីរឿងដល់ថ្ងៃ គេបើកស្បៀង គេដឹកស្បៀងមកមានប័ណ្ណ គេសម្រាប់បើកមានប៉ុន្មានៗចឹងទៅណា។ ឧទាហរណ៍ថាមនុស្សប៉ុន្មានចឹងប្រធានជំរុំ គេធ្វើទៅ មានប៉ុន្មានចឹង ឧទាហរណ៍ថាចំណូលមាន១០០០ ទៅ២០០០ប័ណ្ណនៅក្នុងខែហ្នឹង ឬក៏មាន ១០០ប័ណ្ណនៅក្នុងខែហ្នឹង គេគ្រាន់តែបើកបន្ថែមមកលើហ្នឹងទៀតទៅ។ អង្គការសហប្រជា ជាតិ សម្រាប់តែដឹកស្បៀងអាហារយកមកឲ្យ ឃុំគ្រងស្បៀង អាហារ ដូចជានៅកន្លែងមន្ទីរ ពេទ្យអីសម្រាប់ព្យាបាលជំងឺអីហ្នឹងណាស់។ ហ្នឹងគ្រប់គ្រងដោយអង្គការសហប្រជាជាតិ ហើយ រួមសហការជាមួយប្រធានជំរុំហ្នឹងឯង។ ប្រធានជំរុំអតីតរបស់ខ្មែរក្រហម ដូចនៅក្រង៉ុក តា សុក គាត់អ្នកគ្រប់គ្រងចឹងណា។

បូលីៈ តាសុកហោ៎?

ពិនៈ បាទ!

បូលីៈ តាសុក គាត់ប្រធានជំរុំ?

ពិនៈ បាទ! នៅសាយអេក នៅជំរុំលេខ៨។

បូលីៈ គាត់អីសុខទៅ?

ពិនៈ មិនដឹងស្អីសុកទេ! តាហ្នឹង ដឹងតែហៅតាសុកៗ។

បូលីៈ អតីតជាអ្វី?

ពិនៈ តាសុក គាត់ដូចកងពលដែរ ដូចកងនៅក្នុងកងពលជាមួយតាកន ជាមួអីដែរ។

បូលីៈ មេកងមេអី?

ពិនៈ បាទ! នៅភ្នំព្រឹក្ស ភ្នំអីហ្នឹង គេបញ្ចូល។

បូលីៈ ពេលដែលគេបញ្ជូនពូទៅក្នុងវិញ គេបញ្ជូនពូមកក្នុងវិញ គេបញ្ជូនមកខាងណាវិញ?

ពិនៈ ខ្ញុំគេត្រូវដឹកមកខាងនេះវិញ ដឹកមក១០០៣នេះវិញ។ ដឹកមកនេះវិញ ដឹកមកចាក់ មកនៅ ឯអូរត្រាវវិញ។

បូលីៈ ដឹកពីអូរក្រង៉ុក មកអូរត្រាវវិញ?

ពិនៈ បាទ!

បូលីៈ គេរើសមនុស្សពីនេះទៅវិញ?

ពិនៈ បាទ! រើសចេញពីជំរុំទៅវិញ គេប្រមូលចេញវិញ មិនមែនគេរើសទេនោះ ។ និយាយថាគេប្រមូលចេញទៅវិញ ។

បូលីៈ ពូអត់មានប្រកែកថាអត់ទៅវិញទេពូ?

ពិនៈ មិនមានចិត្ត ហ៊ានប្រកែកទេ តែទៅណាចេះតែទៅហ្នឹងហើយ ។

បូលីៈ គេឲ្យទៅណា គឺទៅហ្នឹងហើយ?

ពិនៈ បាទ!

បូលីៈ ហើយមកដល់អូរត្រាវហ្នឹងហើយ យ៉ាងម៉េចទៀតទៅពូ?

ពិនៈ ដល់អូរត្រាវ គេហៅរៀនកាលហ្នឹង អគ្គភាពគេត្រូវបើកបង្រៀន គេឲ្យនៅវរសេនាធំ ចំណុះវរសេនាធំឯករាជ្យហ្នឹង និងក្រោមការគ្រប់គ្រងរបស់តាម៉ុកហើយហ្នឹង ។

បូលីៈ បញ្ចូលក្នុងកងពលប៉ុន្មានពូមានចាំទេកាលហ្នឹង?

ពិនៈ មុនដំបូងអត់ទេ! កងឯករាជ្យលេខ១៦ ដែលបញ្ជូនតែម្តង មានគ្នាប្រហែល៧០នាក់ទេ ។ ៧០ ចេញពីក្រដុំកហ្នឹងមក ។

បូលីៈ ១៧០នាក់ហ្នឹងចេញពីក្រដុំកមក?

ពិនៈ បាទ! ១៧០នាក់ ចំរុះ មិនមែនតែក្រដុំកមួយទេ មកបានគេដាក់បញ្ជូនទៅគេបំពេញវរសេនាធំ ។

បូលីៈ ដល់ពេលក្រោយមកគេបញ្ជូនទៅកងពលណា?

ពិនៈ ក្រោយមកបានបញ្ជូនទៅកងពល៨០១ ។

បូលីៈ ៨០១?

ពិនៈ បាទ!

បូលីៈ របស់តាសារឿន?

ពិនៈ បាទ! របស់សារឿន ។

បូលីៈ ពេលដែលធ្វើដំណើរពីក្រដុំកមក១០០៣នេះ ធ្វើដំណើរតាមអី?

ពិនៈ តាមឡាន ។

បូលីៈ កាត់តាមដីខ្មែរ ឬកាត់តាមដីថៃ?

ពិនៈ ឡាន! កាត់តាមដីថៃ ។

បូលីៈ ចេះរហូតហ៎ពូ?

ពិនៈ បាទ! គេដឹកកាត់តាមដីថៃមកដាក់ឯ១០០៣នេះ មួយពាន់អីចឹងទៅ!

បូលីៈ ជិះប៉ុន្មានម៉ោងមកដល់ ពូ?

ពិនៈ    អីយ៉ា១យប់ៗ គិតទៅទល់តែជិតភ្លឺ បានដល់តែម្តង និយាយរួមៗ ដិះឡានពីក្រង៉ុកមក ១យប់តែម្តងៗ

បូលីៈ    ពេលហ្នឹង មក១៧០នាក់?

ពិនៈ    អត់ទេ! មកពេញបន្ថែម មកគ្នា២០នាក់ជាង ជាង២០នាក់ៗ

បូលីៈ    យើងមកចឹង មកទាំងគ្រួសារ ឬមក?

ពិនៈ    មកទាំងអស់! គេដឹកចេញ ទាំងប្រពន្ធ ទាំងកូនអីតែម្តងៗ

បូលីៈ    មកនៅអូរត្រាវនេះពូនេះ?

ពិនៈ    មកនៅអូរត្រាវ មកនៅ៤០ៗ

បូលីៈ    ហ៎ូ៤០ទេហ៎?

ពិនៈ    បាទ! មកនៅ៤០ៗ

បូលីៈ    មកនៅ៤០ នៅម្តុំណាវិញអ៊ឹ?

ពិនៈ    ៤០នៅដីថៃ នៅខាងលិចអូរត្រាវ ទៅពីអូរត្រាវទៅៗ

បូលីៈ    ខាងលិចអូរត្រាវ?

ពិនៈ    បាទ! ខាងលិចអូរត្រាវៗ នេះអូរត្រាវហើយ ខាងលិចអូរត្រាវ មានតែខាងនេះៗ ខាងលិចអូរត្រាវតិច ដើរទៅ១ព្រឹក មិនដល់១ព្រឹកទេៗ ១ក្រវ៉ាត់មាន អង្គភាពគេយកមកពង្រឹកតាមហ្នឹងឯងៗ មាន៩២០ ទៅ១អង្គភាពទៅ, ៨០១,៤១២, ៦១៦, ៨០០ចឹងទៅណាគេចែកជាអង្គភាពៗ ៗ

បូលីៈ    ប្រហែលជាប៉ុន្មានគីឡូដីពីអូរត្រាវ ៤០?

ពិនៈ    ស្មានទេដើរប្រហែលជា២ ម៉ោង ទៅ៣ម៉ោង ប៉ុណ្ណឹង ជិតដែរតាៗ

បូលីៈ    ១ម៉ោង យើងដើរបានប៉ុន្មានគីឡូ ១ម៉ោង? ១ម៉ោង៣គីឡូទេពូ?

ពិនៈ    អា៣ ទៅ៤គីឡូៗ

ថនៈ    ៦ ទៅ៧គីឡូអ្នកដើរលឿនៗ

ពិនៈ    អើថាយើងដើរកាត់ព្រៃចឹងវាមិនបានទេ ប្រហែលជា៣ ទៅ៤ យើងថា៤គីឡូចុះៗ

បូលីៈ    កាត់ព្រៃ?

ពិនៈ    បាទ! សុទ្ធតែព្រៃហើយដីថៃ មិនស្រួល សុទ្ធតែព្រៃៗ

បូលីៈ    ចឹងវាស៊ីខ្ទង់១០គីឡូៗ ប្រហែលជា១០គីឡូពីអូរត្រាវ?

ពិនៈ    ហ្នឹងហើយៗ

បូលីៈ ពូច្បាស់ថា៨០ហ្នឹង នៅខាងលិចអូរត្រាវ?

ពិនៈ បាទ! នៅកន្លែងអូរត្រាវ ច្បាស់!

បូលីៈ ព្រោះនៅខាងកើត យើងមាន៥០ ។ ៥០ យើងមានឈូករុន, ដាំស្វា, ដងទង់, គ-៧, ចង់ក, ហើយបានមកអូរត្រាវស្ទឹងចាន់ៗ ស្ទឹងចាន់នេះ វានៅជ្រាលក្នុងទឹកដីថៃ?

ពិនៈ បាទ!

បូលីៈ អូរត្រាវនេះវានៅកៀក?

ពិនៈ ៨០អូរត្រាវ នៅជិតគ្នាហ្នឹងឯងៗ គ្រាន់ថា៨០វានៅក្នុងអង្គភាព៦១២ទីហ្នឹងណា?

បូលីៈ គេហៅ៨០ចឹងតែម្ដង?

ពិនៈ គេហៅ៨០! ទេមិនដឹងគេហៅយ៉ាងម៉េច ហៅចឹងតាមគេទៅណាៗ

បូលីៈ ជាអូរជាច្រក ឬក៏ជាជំរុំ៨០ហ្នឹង?

ពិនៈ ជាតំបន់អង្គភាព ដូចជំរុំអង្គភាពចឹងណាៗ

បូលីៈ ចឹងមុនពេលដែលពូទៅ ចូលមកខាងក្នុងនេះគេដឹកពូ ពីនេះទៅនេះសិន?

ពិនៈ បាទ! ដឹកមកចុះអីហ្នឹងវិញៗ

បូលីៈ ១០០៣ នែក៎?

ពិនៈ បាទ!

បូលីៈ ពូមកដល់នេះ គេបញ្ជូនពូទៅក្នុងអង្គភាពកងពល៨០១! ហើយទៅបញ្ជូនទៅខាងណា ខាងក្នុងមកខេត្តណា?

ពិនៈ បញ្ជូនទៅធ្វើការនៅស្រុកកំណើតនៅខាងភូមិភាគបូព៌ាចឹង គេបញ្ជូនចុះទៅបូព៌ាវិញៗ

បូលីៈ អ៊ូ! មកខាងព្រៃវែងវិញ?

ពិនៈ អត់! ទៅកំពង់ចាមៗ ទៅកំពង់ចាម ទៅធ្វើការងារនៅព្រមប្រទល់ នែកស្រុកកោះសូទិន ស្រីសន្ធរ មួយជួរព្រំប្រទល់ខេត្តព្រៃវែង ស្រុកពារាំង ដូចស្រុកអីចឹងទៅណាៗ

បូលីៈ ស្រុកស្រីសន្ធរ?

ពិនៈ បាទ! ទៅធ្វើការនៅក្នុងហ្នឹងវិញៗ អាហ្នឹង អង្គភាពគេបំបែកឲ្យនៅព្រំដែនហ្នឹងៗ

បូលីៈ អាហ្នឹងគេឲ្យ?

ពិនៈ បាទ!

បូលីៈ បែកពីកំពង់ចាម មកព្រៃវែង?

ពិនៈ បាទ! ព្រៃវែងៗ

បូលីៈ នៅកំពង់ចាមមានកន្លែងឈរជើងមួយ?

ពិនៈ មាននៅក្នុងតំបន់អស់ហ្នឹង មានច្រើនកន្លែងដែរតា ។ មានកន្លែង៩២០, ៨០១ នៅអាមួយផ្លូវជធាន មួយផ្លូវភ្នំព្រឹក្ស ឈូកក្រសៅអីហ្នឹង ។

បូលីៈ បានន័យថា គេមិនមែនបញ្ជូនពី១០០៣នេះ មក?

ពិនៈ អត់ទេ! អាហ្នឹងទៅតែអន្គភាព ទៅតែកងទ័ពទេ ។

បូលីៈ គេមកជុំគ្នានៅកំពង់ចាមសិន? ទៅចល័ត ហើយបានបំបែកពីកំពង់ចាមទៅស្វាយរៀង?

ពិនៈ បាទ! ហ្នឹងហើយ

បូលីៈ ព្រោះ ខ្ញុំសម្ភាសន៍ពូមួយដូចជាពីណា ខ្ញុំភ្លេចឈ្មោះគាត់ទៅថាកងរបស់គាត់គេបញ្ជូនទៅក្រចេះសិន?

ពិនៈ បាទ! ៩២០ គេក្រចេះ ។

បូលីៈ ៩២០?

ពិនៈ បាទ!

បូលីៈ ហើយបានគេបំបែកមកពីក្រចេះមក ស្វាយរៀង មកព្រៃវែង មកធ្វើការពូ?

ពិនៈ បាទ! នេះហ្នឹង៨០២ហ្នឹង ។ ពួក៨០២ ទៅហ្នឹងដែរ ។

បូលីៈ ៨០២ទៅណាវិញ?

ពិនៈ ទៅធ្វើការនៅស្វាយរៀងដែរ ។

បូលីៈ ទៅស្វាយរៀងដែរ?

ពិនៈ បាទ! មានតែ៨០២, អានេះតាមខ្ញុំដឹង ។

ថនៈ ស្វាយរៀង ម្តុំស្រុកណា រមាសហែក?

ពិនៈ ស្វាយរៀង នៅរមាសហែក! ម្តុំស៊ីង ព្រែកត្នោត ស៊ីងអីហ្នឹង ធ្វើការតាមតំបន់ជាយៗព្រំដែនព្រៃបាះៗហ្នឹង មិនមែនស្រុកអីធំ ។ ដូចខ្ញុំទៅនៅកើតភ្នំពេញអីចឹង មានអីព្រៃនាមដើមរាំង ដើមត្រស់អីរិចៗហ្នឹង ។ អាពេលហ្នឹងមានដេកអង្រឹងកើតទេ មានតែកន្ទេរក្រាលផ្ទាល់ដីដេកតែម្តង ។

ថនៈ ចុះទំនាក់ទំនងគ្នា យ៉ាងម៉េចដែរពូ?

ពិនៈ ទំនាក់ទំនងប្រជាពលរដ្ឋហ៎?

ថនៈ បាទ!

ពិនៈ កាលហ្នឹង! មានអីទេ ប្រជាពលរដ្ឋទៅហ្នឹងវាស្រួលម្យ៉ាងដែរ យើងទំនាក់ទំនងប្រជាពលរដ្ឋទៅទៅទាក់ទងជាមួយគាត់ទៅ ហើយគាត់ទិញស្បៀងទិញអីឲ្យចឹងទៅណា ។

បូលីៈ អ៊ីជាកាតព្វរបស់យើងចុះទៅធ្វើការក្នុងហ្នឹងពូ?

ពិនៈ កាតព្វកិច្ចកាលហ្នឹងនែក អ្នកចុះទៅក្នុងនោះ មិនមានអីច្រើនទេ ទី១គ្រាន់តែអប់រំគាត់ខាងនយោបាយឲ្យគាត់យល់ ពីបញ្ហាការតស៊ូតែប៉ុណ្ណឹងទេ ។ សកម្មភាពវាយអីហ្នឹង វាទល់មានការប៉ះទង្គិចខ្លះអីចឹងទៅ ទប់ស្កាត់ទៅ ។ តែបើទៅធ្វើសកម្មភាពអីវាយលុកធំតែម្តងគ្មានទេ តែសំខាន់ជួបប្រជាពលរដ្ឋ អប់រំប្រជាពលរដ្ឋ ហើយការពារប្រជាពលរដ្ឋ តែប៉ុណ្ណឹងទេ ។ ការពារដូចជា ចោរលួច ចោលប្លន់ ឬក៏សកម្មភាពអីផ្សេងទៅៗ យើងសហការណ៍ការពារឲ្យគាត់ចឹងទៅ ណា ។

បូលីៈ ពូធ្វើដំណើរមកចឹង មកដល់ហ្នឹងចំណាយពេលប៉ុន្មានបានដល់?

ពិនៈ កន្លះខែ ។

បូលីៈ ដើររហូត?

ពិនៈ ដើររហូត ។

បូលីៈ ដើរកាត់ព្រៃតែម្តង?

ពិនៈ កាត់ព្រៃ ។ កាត់ពីនេះទៅ ឆ្លងទឹកដីកំពង់ធំ ឆ្លងក្រចេះ ហើយបានចូលកំពង់ចាម ដល់កំពង់ចាមហើយបានបំបែកចេញទៅចុះទៅកោះសូទិន ចុះទៅស្រីសន្ធរ ចុះទៅ ចុះទៅស៊ីធរកណ្តាលពារាំងអីណា ។ អាហ្នឹងកាត់ទៅ ឆ្លងកាត់ជិះឡានមួយយាយអីទៅស្រុក គ្រាន់តែអាកន្លែងឆ្លងទៅឈប់ឲ្យគាត់មើល ។ ឆ្លងនៅខាងកើតកំពង់ចាម ឆ្លងអាម្ដុំមាត់ឃ្លង ជួនកាលឆ្លងក្បែរអាម្ដុំប្ញុកកុប នៅក្បាលស្ពានហ្នឹង ។

បូលីៈ អត់ខ្លាចយួនទេ?

ពិនៈ ទេ! ដូចជាធម្មតា ដល់ចឹងវាស៊ាំហើយ ។ ខាងណាក៏ប៉ះទៅ ក៏វាយទៅ ខ្លះទៅក៏ឆ្លងផុតទៅ ។ ជួនការទៅដេកជិតផ្លូវជាតិហ្នឹង ដេកព្រៃឬស្សី ដេកលបអើតមើលអីចឹងទៅ ។ ពេលណាស្ងាត់ទៅ យើងឆ្លងទៅ ប៉ុន្តែកម្លាំងតូចចឹងដែរទេ ។ កម្លាំង១០ ទៅ ២០នាក់ ។ កម្លាំងតូចៗ ងាយស្រួលចល័ត ។

បូលីៈ បើសិនជាមានរបួសអីទៅ យើងសែងទៅណា?

ពិនៈ របួសយើងសែង ទៅក្រោយវិញ ទៅព្រៃធំ កំពង់ចាមអី ។

បូលីៈ ជំរុំរបស់យើង?

ពិនៈ ទៅហ្នឹង! ទៅវះកាត់នៅហ្នឹង តែប៉ុណ្ណឹងឯង ។

បូលីៈ ចុះជំរុំធំហ្នឹងយួនរកអត់ឃើញហោ៎អឹ?

ពិនៈ ចល័តដែរ ជួនការអាកន្លែងខ្លះយួនវាដូចជារុកអត់ដល់ដែរ ព្រៃវាក្រាស់ដែរធំដែរ ។ ដីកំពង់ចាមពីមុនវាធំណាស់ មិនព្រៃតូច ប៉ុនឥលូវអស់រលីងហើយ ខ្ញុំទៅលេងកន្លែងចាស់ៗហ្នឹង សុទ្ធតែចម្ការកៅស៊ូហើយ ។

បូលីៈ អស់ហើយឥលូវ?

ពិនៈ ខ្ញុំទៅលេងដែរ កន្លែងសមរភូមិខ្ញុំធ្លាប់នៅទៅជួបអ្នកស្រុកជួបអី ទៅគាត់ហ្នឹងណាស់ធម្មតាទៅ ។ យើងវាអង្គភាព យើងមិនចេះដែរទៅទំនាស់ជាមួយអ្នកស្រុកទេ កងទ័ព ។

បូលីៈ ពូចុះមកម្តង ប៉ុន្មានឆ្នាំ?

ពិនៈ ចុះទៅហ្នឹង?

បូលីៈ បាទ!

ពិនៈ ចុះទៅលើកដំបូងចូល៣ឆ្នាំ បានឡើងមកវិញ គេឲ្យទៅហ្នឹង នៅកំពង់ចាមចុះធ្វើការមួយជួរហ្នឹង រហូតទៅរួមសហការណ៍ជាមួយ៨០២ចុះទៅធ្វើនៅកាន់ស្រុកពញ៉ាក្រែកទៅម្តុំ បុស្សរបេក ម្តុំភូមិស៊ីង ភូមិអី ។ ទៅធ្វើការនៅព្រំប្រទល់កំចាយមារ ខាងរមាសហែកអីហ្នឹង ។

បូលីៈ អត់នឹកប្រពន្ធកូនទេណ៎?

ពិនៈ ហ៎! កុំនិយាយមិននឹកនោះ នឹកណាស់មិនដឹងធ្វើម៉េច ។

បូលីៈ មានដែរសុំគេមកវិញទេ?

ពិនៈ អត់ដែរហានទេ ទាល់តែគេតម្រូវឲ្យមក ។

បូលីៈ ម៉េចយើងមិនសុំគេ?

ពិនៈ ដូចជាទម្លាប់របស់កងទ័ព កាលហ្នឹងដូចមិនងាយ ហើយម្យ៉ាងទៀតយើងសុំមក ក៏មិនដឹងថាមកយ៉ាងម៉េច ទោះគេមកជាអង្គភាព បានគេមកបាន មិនមែនមកតែយើងកើតទេ ។

បូលីៈ មក៣ឆ្នាំពូ?

ពិនៈ បាទ! មាន៣ឆ្នាំ មាន១ឆ្នាំ មាន១ឆ្នាំជាងអី ។ តាមពេលវេលាណាដែរមេត្រូវ ខាងលើមេហៅមករៀនទេដែលយើង ត្រូវមកជាមួយទៅក៏មកទៅ ។

បូលីៈ ពេលដែលវៀតណាមដកចុងឆ្នាំ៨៩ហើយខាងខ្មែរក្រហមយើងវាយបានអន្លង់វែង ត្រពាំងប្រាសាទ ពូនៅណាពូ?

ពិនៈ ពេលហ្នឹង ខ្ញុំនៅទំបន់ដាច់ អង្គភាពខ្ញុំ៨០១ ចុះមកពង្រីកមូលដ្ឋាននៅភ្នំដាច់ ។

បូលីៈ ហើយពូលមានបានចូលរួមជាមួយគេទេ?

ពិនៈ អត់ទេ! ខ្ញុំអត់ទេ ។

បូលីៈ ពូនៅឯណា?

ពិនៈ ខ្ញុំនៅឯក្នុងនោះ ។

បូលីៈ ក្នុងកន្លែងណា?

ពិនៈ បាទ! នៅឯកំពង់ចាមនោះ ចុះតែទៅធ្វើការនោះ អត់ដែលសួរបានវាយព្រំដែនទេ ។

បូលីៈ ពេលណាបានគេហៅត្រលប់ទៅវិញ?

ពិនៈ ដូចខ្ញុំថាអាឆ្នាំចុះលើកទី១ ពីឆ្នាំគិតទៅពី៨៦ ។ ៨៥,៨៦,៨៧ ចូល៨៨ បានឡើងមកវិញ ។

បូលីៈ ៨៨បាន មក១០០៣វិញ?

ពិនៈ បាទ!

បូលីៈ បន្ទាប់មកទៀត ។

ពិនៈ បាទ! បាន៣ឆ្នាំ មកជួបគ្រួសារមកជួបអីហ្នឹងណា ។

បូលីៈ ចុះយើងទំនាក់ទំនងតាមជាមួយគ្រួសារយ៉ាងម៉េចទៅពូ?

ពិនៈ ហ៊ូ! ជួបអី ។ តាមទូរលេខ ទូរលេខអា១៥ របស់ចិនណា ខ្ញុំចុចតាមទូរលេខទៅ ចង់សួរសុក ទុក្ខអីតាមទូរលេខ ។

បូលីៈ អាម៉ាស៊ីនទូរលេខមានដែរសេសសល់ទេណ៎ពូណ៎?

ពិនៈ ទេ! ឥលូវដូចជាមិនដែរឃើញទេ មិនដឹងទៅណាអស់ បាត់អស់ហើយទូរលេខហ្នឹង ។

បូលីៈ អាចមាននរណា គេ(ស្តាប់ពុំបាន) នៅសល់ទេ ។

ពិនៈ ទេ! មិនដឹងយ៉ាងម៉េចទេមេធំៗ ប៉ុន្តែដូចជាមិនមានទេ ។ តាមមើលទៅដូចជាបោះបង់ចោល អស់(ស្តាប់ពុំបាន) ព្រោះវាទំនើបទៅៗ ចឹងអាវារបស់ហ្នឹងទៅ ដូចនេះ គេខ្ជិលរវល់ទៅណា យកចោលទៅ ។

បូលីៈ ប៉ុណ្ណាទូរលេខហ្នឹង?

ពិនៈ ទូរលេខ ប៉ុណ្ណេះ ។ មិនធំទេ! ប៉ុនណ្ណេះទេ ។

បូលីៈ ប្រហែលជាប៉ុន្មានគីឡូ?

ពិនៈ ម៉ាស៊ីនវា ប្រហែលជា៣ ទៅ៤គីឡូស្រាលដែរតា ។

បូលីៈ មិនធ្ងន់ ប៉ុន្មានទេ ។

ពិនៈ ហើយមានប្រើកាណូសម្រាប់បញ្ចូលភ្លើងប្រហែលជា៥ ទៅ៦គីឡូអីហ្នឹង អាហ្នឹងធ្ងន់បន្តិច ដុំភ្លើងណា ។

បូលីៈ បាទ!

ពិនៈ អាហ្នឹងមានអ្នក គេម្នាក់ទៅម៉ាស៊ីនទូរលេខមួយទៅ ខ្សែអីប្រហែលជា៤ ទៅ៥គីឡូទៅ ហើយ អាហ្នឹងតែឈប់ត្រង់ណារវៃ បោះខ្សែត្រង់ហ្នឹងទៅ ចង់សួរទៅណាក៏បានដែរ ។

បូលីៈ ហ៊ូ! រវៃយកភ្លើង ។

ពិនៈ បាទ! បញ្ឆួលភ្លើងទៅ ចាំនិយាយទៅ ។

បូលីៈ បានន័យថាអត់បាប់ប្រើសាំងប្រើអី?

ពិនៈ អត់ទេ! អត់មានប្រើទេ ប្រើដៃរវៃ ។

បូលីៈ ដើម្បីបង្កើតចរន្តអគ្គិសនី ហ៊ូយល់ហើយ ។ ចឹងពូមកវិញ៨៨?

ពិនៈ បាទ!

បូលីៈ ៨៨ ពេលដែលគេវាចូលអន្លង់វែង ពូមានវាយហ្នឹងគេទេ?

ពិនៈ អត់ទេ! ខ្ញុំអត់បានចូលរួមប្រយុទ្ធជាមួយមរភូមិព្រំដែនទេ ។

បូលីៈ ម៉េចចឹង?

ពិនៈ ព្រោះ ខ្ញុំត្រូវមុខសញ្ញានៅនោះ ។ ចឹងមកគ្រាន់តែជួប ពួកខាងលើផ្ញើការងារអី ផ្ញើកងពលអី ឬមួយក៏តាអីហៅទៅជួបទៅរៀនអី១ថ្ងៃ ២ថ្ងៃចឹងទៅ ត្រូវចុះទៅវិញទៀត ។ យ៉ាងយូរ១អាទិត្យ មកដល់លើហ្នឹង មិនដែរបានយូរទេ ព្រោះយើងគេចង់និយាយមិនឲ្យយើងចោលសមរភូមិនោះដាច់ណា ។

បូលីៈ មករៀនហ្នឹង រៀនពីអី?

ពិនៈ ការអប់រំ ពេលក្រោយហ្នឹង គ្មានរៀនពីអីទេ រៀនតែពីរឿងយួន សម័យនោះដែលរៀនពីអីខុសពីហ្នឹង ។

បូលីៈ រឿងយួនមួយតែម្តង?

ពិនៈ បាទ! ហ្នឹងហើយ ។

បូលីៈ យួនឈ្លានពាន?

ពិនៈ បាទ! ហ្នឹងហើយ ។

បូលីៈ ពូមានចាំខ្លឹមសាគេទេពូ?

ពិនៈ ទេ! ខ្លឹមសារ មានអីទៅមិនចាំ ប៉ុន្តែគ្រាន់តែថា ការអប់រំពីរឿងយួន ពីរឿងទឹកដី ព្រំប្រទល់ទឹកដីចឹង ព្រំដែន មិនថាខាងលិច មិនថាខាងកើតទេ ថាគេអប់រំ ពីរឿងការពារទឹកដី យុទ្ធសាស្ត្រតែម្តង ។

បូលីៈ ចុះពេលដែលវាយបានពូ ចុះមកនៅទំនប់ដាច់ហ៎ពូ?

ពិនៈ បាទ! ចុះមកទំនប់ដាច់នៅឆ្នាំ៩០, ៩១ហ្នឹង បាទ! ចុះមកនៅហ្នឹង ។ គេហៅភូមិអន្តភាពនៅហ្នឹង ។

បូលីៈ ដែលចុះហ្នឹង កាលហ្នឹងពូនៅឯណា នៅភូមិ៤០ហ៎?

ពិនៈ កាលហ្នឹងចល័តមកនៅឯនេះហើយ ត្រលប់មកនៅជាំស្វាវិញហើយ ។

បូលីៈ មកខាងឈូករុនវិញ?

ពិនៈ បាទ! មកខាងឈូករុនវិញចុះតាមហ្នឹង ។

បូលីៈ ពេលដែលពួចុះមកពួចុះមកតាមណា?

ពិនៈ តាមឈូករុន ។

បូលីៈ មិនចុះតាមច្រក ជាំស្រនាំនេះទេ?

ពិនៈ អត់ទេ! ចុះតាមឈូករុនវិញ ។

បូលីៈ អ្នកដែលគេនៅអន្លង់វែង គេចុះតាមច្រកជាំស្រនាំហ្នឹងទៅ?

ពិនៈ បាទ!

បូលីៈ អ្នកដែលនៅខាងជាប់ជាំស្វា ចុះនៅតាមឈូករុនទៅ ។ យើងអាច មានន័យថាបេះទេពួ អ្នកដែលនៅខាងជប់មួ គេចុះមកតាមជាំស្រនាំ?

ពិនៈ បាទ!

បូលីៈ អ្នកដែលនៅខាងអូរត្រាវមួយចំនួន ខ្ញុំសម្ភាសន៍គេថាចុះមកតាមជាំស្រនាំ ។

ពិនៈ បាទ! ខាងអូរត្រាវ ។

បូលីៈ អ្នកដែលនៅខាងជាំស្វា មកតាមឈូករុន?

ពិនៈ បាទ!

បូលីៈ បើតាមមើលអ្នកដែលចុះតាមជាំស្រនាំ អ្នកនៅតាមឈូករុនមួយណាច្រើនជាង ។

ពិនៈ ហ៊ូ! នែកច្រកខាងជាំច្រើនជាង ។

បូលីៈ ហេតុផលអី?

ពិនៈ ខាងនេះមានអគ្គភាព ដូចមានតែ២ទេ ដែលត្រូវចុះណា ។ មានអគ្គភាព៦១២មួយ និងអគ្គភាព៨០១មួយដែលចុះមកនៅឈូករុនហ្នឹង ហើយហ្នឹងមកនៅទំនប់ដាច់ ។ អគ្គភាព៨០១ចុះមកនៅទំនប់ដាច់តែម្តង ចុះចូលមកនៅជ្រៅជាងគេដង ។

បូលីៈ ៨០១?

ពិនៈ បាទ! ទាំងមេកងពល ទាំងអីហ្នឹងមកនៅហ្នឹងទាំងអស់ ។

បូលីៈ កាលដែលដំបូង ត្រពាំងប្រាសាទមកនៅអន្លង់វែងយើងបែកចែកគ្នា ប្តុក៏គេហៅអន្លង់វែង អន្លង់អី?

ពិនៈ	កាលហ្នឹងគេអត់នេះទេ ពីមុនអត់មានគេបង្កើតជាស្រុកទេ ។ មុនដំបូងគេ មានតែជាលេខអង្គភាពទេ ដូចជាលេខអង្គភាពនៅត្រពាំងប្រាសាទនេះវា៨០២ចឹងណា ។ អាហ្នឹងនៅត្រពាំងប្រាសាទ ហើយដល់៨០១ ចឹងនៅទំនប់ដាច់ ។ ៦១២ ចឹងទៅនៅនែករុនចឹងណា ។

បូលីៈ	ចឹងបានន័យថាអត់ទាន់មានឈ្មោះត្រពាំងប្រាសាទ?

ពិនៈ	បាទ! មុនដំបូងអត់ទាន់មានទេ ។

បូលីៈ	ចុះស្រុកអន្លង់វែង?

ពិនៈ	អត់ទាន់មាន ដូចគ្នា មានតែអង្គភាព៩៨០ ហ្នឹងចឹងណា ៧៨៥ ចឹងទៅ ។

បូលីៈ	បានន័យថានៅពេលដែលយើងហៅអន្លង់វែងហ្នឹងគឺ បូកហ្នឹងត្រពាំងប្រាសាទចូលរួចហើយ ហើយតំបន់អន្លង់វែងតូ?

ពិនៈ	បាទ! អាហ្នឹងគេអត់ទេ ដល់ពេលក្រោយមកបានគេចែកជាស្រុក ដល់ពេលក្រោយបង្កើតអង្គភាពចុះនៅសិប់ នៅក្នុងតំបន់ព្រំដែនហើយ បានគេបង្កើតស្រុក២ហ្នឹង គេហៅស្រុករបស់ខ្មែរក្រហម អាហ្នឹងអត់ចាំទៀត មិនដឹងជាកើតឆ្នាំប៉ុន្មានទេ ចាំតែអង្គភាពទេ ។

បូលីៈ	ចុះមកដំបូងអត់ទាន់មានឈ្មោះស្រុកអន្លង់វែង?

ពិនៈ	បាទ! អត់ទេ ។

បូលីៈ	ទាល់តែពេលតាម៉ុក ដឹកនាំកម្លាំងចុះមកអស់ហើយបានគេបង្កើតតាមក្រោយ?

ពិនៈ	បានគេបង្កើតតាមក្រោយ បង្កើតជាស្រុក ។

បូលីៈ	មានស្រុកពីរចឹងណ៎?

ពិនៈ	បាទ! មានស្រុកពីរហ្នឹងហើយ ។

បូលីៈ	ទី១ ស្រុកអន្លង់វែង ទី២ស្រុកត្រពាំងប្រាសាទ?

ពិនៈ	បាទ! ហ្នឹងហើយ ។ ចុះគណៈស្រុក ត្រាពាំងប្រាសាទនេះបងប្រធានក្រុមប្រឹក្សា បងបណ្តូលបងសារិនហ្នឹង គាត់ហ្នឹង ក្នុងនាមគណៈស្រុកហើយហ្នឹង គាត់ពិការ ហើយគេឲ្យធ្វើចឹងទៅណា ។ អ្នកណាដែលដើងល្អ ខ្ញុំនេះគេឲ្យចុះទៅឆ្ងាយ ចុះទៅការងារខាងក្នុងហើយ ក្នុងហ្នឹងណា ។

បូលីៈ	ចឹងមកខាង ត្រពាំងប្រាសាទនេះ តាមមើលដូចជាមិនច្រើនដូចខាងអន្លង់វែងទេ?

ពិនៈ	ទេច្រើនដែរ ។

បូលីៈ	ប៉ុន្មានកងពលទៅ?

ពិនៈ	ពេលក្រោយមកត្រពាំងប្រាសាទហ្នឹងមាន ដូចនែ៎កកងពល៨០០, ៨០១,៨០២, ៦១២, ៤១៧ ច្រើនកងពលដែរ ។ មើលមាន៤១៧,៨០១, ៨០២, ៨០០, ៦១២ នៅអង្គភាព៧០៥ទៀតហេ៎! រតនគិរីហ្នឹង ។

បូលី៖ ១០៥ហេ៎?

ពិន៖ បាទ! ខាង៧០៥ ។

ផន៖ ៦កងពល ។

បូលី៖ ៦កងពលហេ៎! ៧០៥ ឬក៏(ស្តាប់ពុំបាន)? កងពលដែលចុះមកខាងត្រពាំងប្រាសាទ?

ពិន៖ កងពលហេ៎ ៨០០, នែក៨១៧ តែដូច៧០០ហ្នឹងហើយ ខាងតាប្រ៉ូ ។

បូលី៖ ខងជនជាតិហ្នឹងហេ៎?

ពិន៖ បាទ!

បូលី៖ ខាងតាអនស៊ី តាសារុនអីហ្នឹង?

ពិន៖ បាទ!

បូលី៖ ១០៥ ។ ព្រោះអត់មានលេខ ៧០៥ផង ។

ពិន៖ បាទ! ១០៥ហើយចឹង ។

បូលី៖ ចុះខាងត្រពាំងប្រាសាទហ្នឹង?

ពិន៖ បាទ! ត្រពាំងប្រាសាទហ្នឹង ។

បូលី៖ ចុះ៨០១ នៅក្នុងឃុំអីគេ?

ពិន៖ ៨០១នៅទំនប់ដាច់តែម្តងនៅខាងកងពល មេបញ្ជាកងពលនៅទំនប់ដាច់ចឹងតែម្តង ។

បូលី៖ ៨០១ នៅទំនប់ដាច់?

ពិន៖ បាទ! នៅអន្តភាពខ្ញុំហើយអាហ្នឹង ស្គាល់ៗច្បាស់ ហើយអន្តភាពខ្លួនឯង ។

បូលី៖ ៨០២?

ពិន៖ ៨០២នៅនេះ ផ្ទះតាឈនហើយនេះ ដីផ្ទះគាត់ ។

បូលី៖ ត្រពាំងប្រាសាទ?

ពិន៖ បាទ! ផ្ទះមេកងពល កន្លែងហ្នឹងស្រះគាត់ នៅឯក្រោយនេះ ដល់ពេលក្រោយមកដាក់សាលាស្រុកហ្នឹង ។

បូលី៖ គាត់អត់យកវិញទេដីហ្នឹង?

ពិន៖ អត់ទេ! គាត់ស្លាប់ហើយ ។

បូលី៖ ៨០០ពូ?

ពិន៖ បាទ! ៨០២ ។

បូលី៖ ៨០០ នៅណាវិញ?

ពិន៖ ៨០០ហួសទៅក្រោម ។

បូលីៈ នៅឯណា?

ពិនៈ នៅក្បែរគ្នាដែរ នៅទំបន់ដាច់ដែរ ។

បូលីៈ នៅទំនប់ដាច់ដែរ?

ពិនៈ បាទ! នៅឯកើត ។ ៤១៧ក៏នៅហ្នឹង គេយកមកបូកគ្នានៅហ្នឹង ។

បូលីៈ ៤១៧ ក៏នៅទំនប់ដាច់ដែរ?

ពិនៈ បាទ!

បូលីៈ ដល់ក្រោយមកទៅនៅទីណាវិញ៤១៧?

ពិនៈ ៤១៧ ទៅនៅអូរស្វាយវិញ ។

បូលីៈ ដូរទៅអូរស្វាយវិញ?

ពិនៈ បាទ! ដល់ក្រោយមក ចប់ទៅបានបែកគ្នានៅបានលុងនេះ ហ្នឹងច្រើនពួកខាង៤១៧ ។

បូលីៈ មកបានលុងដែរ!

ពិនៈ បាទ! ហ្នឹងហើយ ។ ខាង៤១៧ នៅខាងហ្នឹង ។

បូលីៈ ចុះ១០៥ នៅខាង?

ពិនៈ ១០៥ នៅខាងតាអនស៊ី នៅខាងអី១០៥នោះ ។ អ៊ូ! នៅអង្គភាព១ទៀត ៩២០មួយទៀត ។

បូលីៈ ៩២០ មួយទៀត?

ពិនៈ បាទ! ៩២មួយទៀត កងពលនោះ ។

បូលីៈ ៩២០ មិនមែននៅខាងអន្លង់វែងទេណ៎?

ពិនៈ អត់ទេ! ខាងត្រពាំងប្រាសាទដែរ ។

បូលីៈ ១០៥ នៅក្នុងឃុំអីចូ? ផ្អាវហ៎ចូ?

ពិនៈ ផ្អាវ ។

បូលីៈ ផ្អាវចូ?

ពិនៈ បាទ!

បូលីៈ ៩២០ ក៏នៅភូមិផ្អាវ ។

ពិនៈ ៩២០ ផ្អាវដែរ?

បូលីៈ បាទ! ៦១២ចូ?

ពិនៈ ៦១២ នៅឈូករុននេះកាលមុន ។

បូលីៈ នៅឈូករុន?

ពិនៈ បាទ!

ប៊ូលីៈ ប៉ុនដល់ពេល ចុះមកចុះនៅឯណាវិញ?

ពិនៈ បងអឿននេះ ។ ចុះមកនៅឈូករុនតែម្ដង ។

ប៊ូលីៈ ព្រះប្រលាយ?

ពិនៈ បាទ! ព្រះប្រលាយ ។

ផនៈ នេះកាមុននៅព្រះវិហារអី? ៦១២?

ពិនៈ ហ្នឹងហើយធ្វើការងារព្រំដែន ។ ៦១២ នៅមួយជួរព្រះវិហារ ។

ផនៈ អិន ហឿន ហ្នឹង?

ពិនៈ បាទ! អ៊ិន ហឿន ។ មេកងពលហើយហ្នឹង ។

ប៊ូលីៈ បេលដែលចុះមកនៅហ្នឹង ថាតើឥលូវខ្ញុំហៅតំបន់អន្លង់វែងចុះ ណាពូ យើងកុំគិតថាស្រុកអន្លង់វែង ឬស្រុកត្រពាំងប្រាសាទ យើងគិតថាទាំងពីរហ្នឹងជិវុំតែមួយចុះ ។ តំបន់ហ្នឹង នរណាគេគ្រប់គ្រងធំជាងគេ ខ្ពស់ជាងគេ?

ពិនៈ មានតែតាម៉ុកហ្នឹង តាម៉ុកហ្នឹង គាត់អ្នកគ្រប់គ្រង មានឃ្លាំងមានអី ស្បៀងមានអីរបស់គាត់ ។

ប៊ូលីៈ តាប៉ុល ពតមកក្រោយគេទេ?

ពិនៈ តាប៉ុល ពត គាត់ទើបតែមកក្រោយទេ មកពីខាងប៉ៃលិននោះ ក្រោយទេ ។

ប៊ូលីៈ តាម៉ុក គ្រប់គ្រងមុនគេ?

ពិនៈ បាទ!

ប៊ូលីៈ ក្រោមតាម៉ុក ពីណាគេ? អនុរបស់តាម៉ុក បើនិយាយឲ្យចំ?

ពិនៈ ដូចជិនាន់ហ្នឹង ដូចមិនមានបែងចែក អនុតាម៉ុកទេ ដឹងថាតាម៉ុក គ្រប់គ្រងបែកខាងហ្នឹង ដឹងតែតាម៉ុកតែម្ដងឯង ហើយក្រៅពីនោះចែកជាកងពលតែម្ដងទៅ ។ ចែកជាកងពល មានកងពល ៨០១, ៨០២, ៨១៧ចឹង, ៦១២, ៦១៦, ៨០០ចឹង១០៥ អីចឹងទៅណា ។

ប៊ូលីៈ ចឹងបានន័យតាម៉ុក គាត់ដូចជា មេធំហើយចឹង! ហើយក្រោមគាត់មកគឺ មេកងពល?

ពិនៈ បាទ! មេកងពល ជាសាខារបស់គាត់ ។

ប៊ូលីៈ ពូមានដឹងពីរឿងដែលគេសម្លាប់តាសុន សេនទេ?

ពិនៈ អត់ទេ! កាលហ្នឹងខ្ញុំនៅក្នុង ។

ប៊ូលីៈ ពូនៅឯណា?

ពិនៈ ខ្ញុំនៅកំពង់ចាម ។

ប៊ូលីៈ ហ៊ូ! គេបញ្ជូនពូទៅនៅក្នុង?

ពិនៈ បាទ! ខ្ញុំអត់ទាន់ឡើងមក ។

បូលីៈ ឆ្នាំ ប៉ុន្មាន?

ពិនៈ អាហ្នឹងឆ្នាំប៉ុន្មានទេហ្នឹង កាលសកម្មភាពហ្នឹង ដូចកើតចុងកន្ទុយឆ្នាំ៩៧,៩៨ ហើយហ្នឹង ។

បូលីៈ ៩៧?

ពិនៈ បាទ! ៩៧,៩៨ ។

បូលីៈ ហ៊ូ! ពេលហ្នឹង ៩៧ ពូនៅក្នុងនៅឡើយទេចឹង?

ពិនៈ បាទ! នៅក្នុងនៅឡើយតា!

បូលីៈ នៅធ្វើការនោក្នុងទៀត?

ពិនៈ បាទ! ក្រោយពីគេ សម្លាប់ហើយ បានគេហៅឡើងមក ។

បូលីៈ គេហៅឡើងមកធ្វើម៉េចទៅ?

ពិនៈ គេហៅឡើងមកដល់នេះ ខ្ញុំនៅក្នុងអង្គភាព៨០១ហ្នឹង គេហៅឡើងមកដល់ គេចាប់ផ្ដើមគេសុំដកអាវុធដកអីមួយសារទៀតហើយកាលហ្នឹង ។

បូលីៈ ពីណាគេកាលហ្នឹង?

ពិនៈ ខាងតាដដែរហ្នឹង ។ ដកអាវុធពីអង្គភាព ចាប់មេចាប់អីទៅបាត់អស់ បងសារឿន បងអីយកទៅ មានតែស្លាប់ គ្មានរស់ទេកាលហ្នឹង តែចាប់ទៅស្លាប់ហើយ ។ ចាប់មេកងពល ៨០១ បងសារឿនហ្នឹង ៨០០ ចាប់តាឃន ចាប់កងពល ៨០១តាសែមហ្នឹង ៩២០ បង០៦ ។ តានួនអីហ្នឹងយកទៅបាត់អស់ ស្លាប់ទាល់តែថ្ងៃនេះ បាត់អស់ ចោលប្រពន្ធចោលកូន ។

បូលីៈ តាខេមរា នៅ៩២០ អនុកងពលអី?

ពិនៈ នៅ៩២០ ។

បូលីៈ គាត់អនុកងពលអីតា?

ពិនៈ អាចរងកងពលហ្នឹងឯង!

បូលីៈ ពេលហ្នឹងហេតុអ្វីបានជាគេអើចាប់តា០៥,០៦អីហ្នឹង?

ពិនៈ អាហ្នឹង តាមមើលគេហៅមកវិញទេ គេហៅមករៀន គេថាពួកក្បត់ពួកអីណា ខ្ញុំមិនដឹងដែរដល់គេថាក្បត់ចឹងទៅតាមដំណើរ ។ លែងហានមាត់ ហើយកាន់តែខ្លាំងទៀតដល់ចឹង ។ សន្ធិមួយព្រឹកដល់ចឹង ដើម្បីជីវិតរស់ណាចឹង ។

បូលីៈ អ្នកណាអ្នកហៅពូត្រលប់មកវិញ?

ពិនៈ កាលហ្នឹងគ្រប់អន្តភាពនៅក្នុង គេហៅឡើងមកសឹងតែទាំងអស់មកផែនការណ៍ក្រោយទៀត តាម៉ុកគាត់រៀបផែនការណ៍ អាផែនការណ៍ពង្រឹងកងទ័ពតាមព្រំដែនឡើងវិញនោះទៀតណា ក្រោយពីសម្ងាប់សុន សេនសម្លាប់អីហើយហ្នឹង ។

បូលីៈ អាហ្នឹង ពេលហ្នឹងចាប់តាសារឿនហើយ នៅពេលពូដើរជាមួយហ្នឹង?

ពិនៈ គេចាប់បាត់ហើយ! ខ្ញុំមកដល់គេចាប់ហើយ មកដល់គេមានឲ្យធ្វើអីណា គេឲ្យនៅផ្ទះធម្មតា មានគេអូចេះតែបើកចាំតែស្តាប់ទៅ មានហាននិយាយផង ។ ខ្ញុំនិយាយដល់រឿងចុងក្រោយវាដូរចត់មែនទែនទៅ ។

បូលីៈ ដូរចត់អីទៅពូ?

ពិនៈ ចឹងដូចត់ពេលក្រោយមក មិនខ្ញុំនាំកម្លាំងកងទ័ព៨៧នាក់ទៅភ្ជាប់ជាមួយរដ្ឋាភិបាល មិនប្រពន្ធអី តាម៉ុក គាត់យកទៅដាក់គុកទាំងអស់កូនប្រពន្ធខ្ញុំ ។ ជាប់គុកយកគោដាក់ហាលវាល ស្រែប្រាំង អាវាលកន្លែងអន្លង់វែងហ្នឹង កាលហ្នឹង ។ ពេលដែលខ្ញុំទៅភ្ជាប់ហើយនឹកឃើញថាវាផ្លូវជ្រើសរើសវាមានតា និយាយរួមខាងហ្នឹងវាមានក្នុងអារម្មណ៍មួយគិតឃើញថា បើនៅមានតែផ្លូវស្លាប់ ពេលនោះគេកំពុងតែហៅឡើងទៅរៀនបន្តៗហ្នឹងណា ។ ហើយកន្លែងគេហៅមេទៅរៀនបន្តៗទៀត ដោយទាំងបងដាកែវ ដោយទាំងតាជុំយើងអី គេមិនហៅទៅឃុំនៅអន្លង់វែងហើយដល់ខ្ញុំនៅក្រោមៗចេះតែក្លាចដែរ មិនគេចខ្លួនទៅនោះ ជាមួតាលៀងជាមួយអីនេះ មេអ៊ីង លាង ។

បូលីៈ អ៊ីង លាង?

ពិនៈ បាទ! តែឥលូវគាត់ទារុណគ្រាហើយ ។ កាលហ្នឹងគាត់រងកងពល ជាមួយតាលាងជាមួយអីនេះមេ អ៊ីង លាង ។ គេឲ្យទៅវាមួយដូរអានេះ អាហ្នឹងអាហ្នឹងគេចាប់ផ្តើមផែនការថ្មីហើយ ។ ហើយ ដល់ហើយខ្ញុំទៅ ខ្ញុំនឹកឃើញថា មិនដឹងជាច្បាំងអីទៀត បើច្បាំងទីចុងបំផុត បានត្រឹមតែ គេវាយចោល និយាយឲ្យខ្លីសរុបមកវិញណា ។ ក៏ទៅភ្ជាប់ជាមួយរដ្ឋាភិបាលទៅ ផ្តាច់ខ្លួនទៅ មួយដុំងទៅ ។

បូលីៈ ពីណាគេអ្នកផ្តួចផ្តើមក្នុងការផ្តាច់ខ្លួន?

ពិនៈ ផ្តួចផ្តើមទៅ?

បូលីៈ បាទ! ចុះចូលជាមួយរដ្ឋភិបាល?

ពិនៈ មានបងលាង មានខ្ញុំ មានឡេង ហរិញ្ញវត្ថុគាត់កងពលលេខ៨៧រាល់ថ្ងៃនេះ ចេះតែជិនុំគ្នាទៅណា ។ ឥលូវបើយើង ជ្រើសរើស បើយើងទៅ យើងមានផ្លូវ២ ទី១ជាប់គុក ទី២រស់តែបើយើងនៅ យើងមានតែផ្លូវ១ទេ មានតែផ្លូវស្លាប់ ដល់ចឹងយកអាណា នេះការពិគ្រោះ

គ្នាណាជាមួយគាត់ហ្នឹង យើងនិយាយលេងចឹង ការជ្រើសរើស មានន័យថា ខ្ញុំថាផ្លូវសុខចិត្តជ្រើសរើសរកផ្លូវ២រស់នឹងជាប់គុក អាហ្នឹងសុខចិត្តថាជាប់គុកទៅចុះ ក្រែងលោវាបានរស់ជួបកូន ជួបប្រពន្ធណា បើនៅវាមានតែផ្លូវស្លាប់មួយ ចឹងវាគេចអត់ផុតទេ ។ ចឹងវាទៅតាមហ្នឹង ។

បូលីៈ គំនិតក្នុងការចុះចូល មានតាំងពីណាមក ឬក៏ទើបមានថ្មីនេះ?

ពិនៈ ទើបតែមានថ្មីៗ ។

បូលីៈ ពេលដែលគេសម្លាប់សុន សេនចោល?

ពិនៈ បាទ! ហ្នឹងហើយ ។ គំនិតហ្នឹងវាមានពេលកិច្ចព្រមព្រៀងប៉ារីស និយាយរួមទៅវាមានការប្រែប្រួល ។

បូលីៈ ប៉ុន្តែម៉េចក៏ពូមិនចុះចូលតាំងពីឆ្នាំ៩១មក?

ពិនៈ មិនហ៊ាន! ចេះតែខ្លាច ព្រោះធម្មតាយើងរស់នៅជាកងទ័ព ប្រយុទ្ធច្បាំងយើងចេះខ្លាចទៅ ខ្លាចគេមិនទុកឲ្យយើងរស់ណា ឬមួយក៏ទៅចាត់ទុកដូចយើងថាជាឈ្លើយសឹក ហើយទៅយើងបែកប្រពន្ធបែក បែកកូនផង ម្យ៉ាងវាជាបល់និស្ស័យប្រពន្ធហើយហ្នឹងកូននៅឯនេះ ។ បើយើងទៅរួចតែខ្លួនយើង ចោលកូនចោលប្រពន្ធ ចឹងមនោសញ្ចេតនាវាជ្រាលជ្រៅណាស់ដែលយើងមិនអាចទៅណាបាន ។ ដល់ចឹងយើងចេះតែទ្រាំនៅទៅណា ។

បូលីៈ តើអ្វីដែលជាដែលជាកំសួលចិត្តជុំរុញពូឲ្យ ធ្វើការចុះចូលនៅឆ្នាំ៩៨ ពូអាចបញ្ជាក់ម្តងទៀតបានទេ?

ពិនៈ ហ៊ូ! គេលើកទឹកចិត្តដែលជាទស្សនៈគេនោះយល់ឃើញថា អ្នកដែលទៅភ្ជាប់ជាមួយរដ្ឋាភិបាល យើងអាចដឹងថាភាគច្រើន វាមិនស្លាប់ រស់!អីចឹងទៅណា វាប៉ុណ្ណឹងឯង ចឹងយើងមានទំនុកចិត្តមួយកក់ក្តៅ ថាយើងទៅភ្ជាប់ជាមួយរដ្ឋាភិបាលទៅ វាបានរស់ តែបើយើងភ្ជាប់ទៅជាមួយ នៅនេះទៅ គេចោទថាយើងក្បត់យើងមិនអាចរស់បានទេ ត្រូវតែស្លាប់តែម្តងចឹងណា ។ ចឹងទាល់តែបន្ទំចិត្តទើបភ្ជាប់ជាមួយរដ្ឋាភិបាល ហើយពេលនោះយោងទៅតាមការស្តាប់ខ្លះអីខ្លះ គេហៅថាមានការយោគយល់អនុគ្រោះរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលគេនោះ ដែលមានចំណុចទី១ គេមិនឲ្យយើងបាត់បង់តួនាទី ទ្រព្យសម្បត្តិ អាយុជីវិតគេចឹងណា ចឹងយើងវាកក់ក្តៅទីហ្នឹងឯង ដែលជាគោលនយោបាយឈ្នះៗនោះ ។ មនុស្សយើងវាចេះគិតហើយអាហ្នឹង រស់កាន់តែលំបាក កាន់តែគិតច្រើន តែបើបីមុនគេមិនឲ្យយើងស្តាប់ទេ ព្រោះវិទ្យុអីមានក៏យើងអត់មានទោស្តាប់អត់អីបានទេន៎ ស្តាប់ទាល់តែយើងលួចលាក់អាថកំបាំងអីខ្ទស់ណាស់ ប៉ុនយើងស្តាប់បាន ។ យើងនិយាយរួមវិទ្យុវាមិនដែរបើកឲ្យយើងទេ គេឲ្យតែមេៗផង ។

បូលីៈ ពេលដែលពូរត់ ទៅចុះចូលពូទៅជួបពីណា ចុះចូលជាមួយពីណា?

ពិនៈ ជាដំហានដែលទៅភ្ជាប់ ទៅខេត្តព្រះវិហារនោះ មិននឹងឃើញថាទៅជួបនរណាទៀតទេ ប៉ុនទៅភ្ជាប់ជាមួយរដ្ឋាភិបាលទៅទាំងអាវុធទាំងគ្រាប់ ទាំងកាំភ្លើងអីទៅ ទាំងកំប្លេ ឲ្យទៅច្បាំង ហួសទៅនឹកឃើញថា ទៅសុំភ្ជាប់ជាមួយរដ្ឋាភិបាលពេលនោះតែម្តង ហើយមានការទំនាក់ទនងជាមួយនឹងខេត្តព្រះវិហារ កាលហ្នឹងដូចតាហួរ គាត់នៅចៅហ្វាយខេត្ត ។

បូលីៈ ស្អីគេហួរ?

ពិន ៈ ស្អីគេហួរទេ! ចៅហ្វាយខេត្តហ្នឹង ហើយទាក់ទងជាមួយកងពល ខាងតាស្រីដឹក ។

បូលីៈ តាមខាងស្រិដឹក?

ពិនៈ បាទ! ទាក់ទងគ្នាតាម គេអូរចុះឡើងៗហើយណ៎!

បូលីៈ បាទ! ប៉ុនមុនពេលដែលទៅទាក់ទងស្រីដឹកទៅខាងព្រះវិហារ ពូដឹងថាបុគ្គលមួយណាដែលពូទៅទៅនិយាយជាមួយ ទៅចុះចូលជាមួយ?

ពិនៈ ពេលហ្នឹងដូចមិនមានអីទេ! ដូចជាថាមិននឹកឃើញអីទេ ទាក់ទងបុគ្គលណា ដែលទៅហ្នឹង ទៅទាក់ទងអ្នកណាក៏ដោយឲ្យតែមានការទំនាក់ទងនង បេះតែទៅៗណា ។ ហើយយើងទៅជាអគ្គភាព ពេលទៅហ្នឹង វាស្ថិតក្នុងសភាពព្រួយដែរ មិនមែនអត់ព្រួយទេ វាចឹង បានតែយើងចង់និយាយតែក្នុង គិតទៅយើងតាំងចិត្តថាយើងមិនទៅធ្វើអីគេចឹងហ្នឹង ទោះបីយើងមានអាវុធក៏ដោយ បើសិនជាគេធ្វើអីយើងក៏ធ្វើទៅ យើងនិយាយចឹង ។

បូលីៈ មានន័យថាជួបនរណានិយាយជាមួយអ្នកហ្នឹងតែម្តង?

ពិនៈ បាទ! ជួបនរណានិយាយជាមួយអ្នកហ្នឹងតែម្តង ។

បូលីៈ មានដែនការណ៍អីសំងាត់ អីទេ?

ពិនៈ បាទ! អត់ទេ ។

បូលីៈ យើងអត់ទាក់ទងគ្នានិយាយគ្នា វាយជាមួយអីអត់ទេ?

ពិនៈ បាទ!អត់ទេ ។ ទាល់តែភ្ជាប់ហើយ បានរៀបចំកម្លាំងមកវាយវិញ ។

បូលីៈ ពេលពូដឹកនាំកម្លាំងគេទៅ ប៉ុន្មាននាក់?

ពិនៈ ៤៧នាក់ ។

បូលីៈ មានគ្រួសារទេ?

ពិនៈ មានគ្រួសារភាគច្រើនដែរ ។

បូលីៈ ទៅទាំងគ្រួសារពេញហ្នឹង?

ពិនៈ	អត់ទេ! អត់ទៅទាំងគ្រួសារទេ ៗ គ្រួសារតាម៉ុកយកទៅដាក់គុកទាំងអស់ហ្នឹង ប្រពន្ធកូនមានរត់អីរួច រត់ទៅតែខ្លួនឯងហ្នឹងណា ៗ

បូលីៈ	ទៅដល់ដំបូងជួននរណាគេ?

ពិនៈ	ទៅដំបូងជួបនៃកខាងកងពលតាដីកអ្នកទៅទទួលយកណា!

បូលីៈ	បាទ!

ពិនៈ	ខាងកងពលតាស្រីដីកហ្នឹង អ្នកទៅទទួលផ្ទាល់តែម្តង ដឹកស្បៀងដឹកអីតែម្តងយកទៅឲ្យហ្នឹងពីដើមទៅអីហ្នឹងនៃក ទៅថៅហ្វាយខេត្តព្រះវិហារ អ្នកទៅទទួល ៗ

បូលីៈ	បច្ចុប្បន្នថៅហ្វាយខេត្តកំពតហ្នឹងអី?

ពិនៈ	ប្រហែលទៅហ្នឹងហើយមិនដឹងតាហ្នឹងហើយ!

បូលីៈ	ឈ្មោះ (ស្តាប់ពុំបាន) ហួន ៗ

ពិនៈ	ហ្នឹងហើយ! កាលមុនគាត់នៅព្រះវិហារកាលហ្នឹង៩៨ ៗ

បូលីៈ	យុយ យុនហួរ?

ពិនៈ	បាទ!

បូលីៈ	ឥលូវហ្នឹង គាត់ធ្វើថៅហវ៉ាយខេត្តកំពត បាទ! គាត់រាងស្គមខ្ពស់ ដូចពូចឹង!

ពិនៈ	គាត់រាងដូចចិន ចឹង ៗ

បូលីៈ	ចុះតាជុំ ចិន នៅឯណា តាជុំអី?

ពិនៈ	តាជុំគាត់ទៅមុន ទៅមុនខ្ញុំជាមួយតាកែវ ៗ គាត់រត់មួយគន្លះ ទៅហើយ ហៅទៅជាមួយហ្នឹងផ្នែកបើបានតែគាត់ទៅហ្នឹង គាត់សុខសាន្តហើយណា ៗ បានខ្ញុំទៅជាអគ្គភាព តទៅក្រោយទៀត បើយើងទៅក្រោយទៀត ៗ

បូលីៈ	ទៅជួបតាកែវហើយ បានទៅទាក់ទងទៅហ្នឹងមុនហើយនៅព្រះវិហារហ្នឹងណា បានទៅតាមរយៈហ្នឹង ប៉ុណ្ណឹងឯង ៗ

ពិនៈ	ចុះនរណាអ្នកវ៉ាយអយគួម ថាត្រូវចេញទៅពេលណា?

បូលីៈ	ពេលហ្នឹង វិទ្យុទាក់ទងគឺ យើងសេរីដែរ យើងទៅធ្វើការងារ យើងចង់ទំនាក់ទំនងទៅណាក៏បានចង់ទាក់ទងទៅចឹងណា៎ និងមានអីទេ ៗ ចឹងទាក់ទងចង់ឲ្យតែគាត់បានសេចក្តីសុខ គ្រាន់តែសួរសុខទុកធម្មតាទៅណា តាកែវ តាអី ព្រោះតាកែវ មេកងពលខាង៨០១ អើ! ដូចគាត់អនុកងពលចឹងណា បន្ទាប់ពីតា០៥?

ពិនៈ	ហ្នឹងហើយបន្ទាប់ពីតា០៥ហ្នឹង គាត់ហ្នឹងឯង ៗ

បូលីៈ	ពេលដែលយើងទៅហើយ យ៉ាងម៉េចយើងទៅវ៉ាយ(ស្តាប់ពុំបាន)យ៉ាងម៉េច?

ពិនៈ បាទ! មកវិញ សុំរដ្ឋាភិបាល ជួយគាំទ្រ មកវាយដើម្បីយកប្រពន្ធកូនវិញ ។

បូលីៈ ពូមានកម្លាំងខាងខ្មែរក្រហមគេ?

ពិនៈ នែកដល់ទៅដល់ជុំគ្នាហ្នឹង មានកម្លាំងដល់ទៅ៧០ជាង ។ ៧០នាក់ជាង! អាហ្នឹងនៅព្រះវិហារហ្នឹង ត្រូវរៀបមុខសញ្ញា រៀបចំមកវិញហ្នឹង ។

បូលីៈ ជាង៧០ទេ?

ពិនៈ បាទ! ជាង៧០ ។

បូលីៈ ទាំងកម្លាំងតាជុំ ទាំងតាកែវ?

ពិនៈ បាទ! កម្លាំងតាជុំ ហើយតាកែវទៅ៧០ជាង ។

បូលីៈ ហើយរដ្ឋាភិបាលគេឲ្យកម្លាំងថែមប៉ុន្មាន?

ពិនៈ រដ្ឋាភិបាល មានកងពលលេខ១ កងពលលេខ២ហ្នឹង តាដីកហ្នឹង មកជាមួយដែរ ប៉ុន្មានកងពលហ្នឹង ហើយកងរថក្រោះកងអីហ្នឹងមកជាមួយ ។ ហ៎! មួយកងពល១ មិនដឹងជាប៉ុន្មានទេកាលហ្នឹង ហ្នឹងឯង ។

បូលីៈ ច្រើនទេ?

ពិនៈ ច្រើនតា ។

បូលីៈ គេចែកប៉ុន្មានមុខសញ្ញា?

ពិនៈ ចែកមុខសញ្ញាហ្នឹងមកពីហ្នឹងមានមុខសញ្ញាវាយចូលតាមច្រកពិសេស ចូលព្រះវិហារ ចូលមកទំនប់ដាច់យើងនេះ ចូលមកត្រពាំងប្រាសាទវាមានបួនច្រក ។

បូលីៈ មានច្រក វាយចូលមកនេះ ។

ពិនៈ ខ្ញុំសូមពូបញ្ជាក់ម្តងទៀត មានបួនច្រក?

បូលីៈ បាទ! ច្រកទី១?

ពិនៈ ច្រកចូលតាមអានសេះ ។

បូលីៈ ហ្នឹងវាយចុលតាមអានសេះ ។

ពិនៈ ហ្នឹងរៀបចំកម្លាំង ។

បូលីៈ យើងវាយ យើងវាយយកអន្លង់វែងចឹង?

ពិនៈ បាទ! នៅមិនទាន់ឈានចូលដល់អន្លង់វែងទាំងស្រុងទេ យើងរៀបចំពីកើតមក រៀបចំត្រឹមហ្នឹងទេ ។ ខាងអន្លង់វែង វារៀបចំខាង!

បូលីៈ ប៉ុនខាង(ស្តាប់ពុំបាន) គ្រប់គ្រងខាងអន្លង់វែង និងត្រពាំងប្រាសាទ?

ពិនៈ បាទ! ហ្នឹងហើយ ។

បូលី៖ ហើយអានសេសនៅខាងណាណីវិញ?

ពិន៖ អានសេស ក៏តំបន់ព្រំដែនខ្មែរក្រហមដែរ ព្រះវិហារក៏ពួកគាហៀននៅហ្នឹង ។

បូលី៖ ហ៊ូ! នៅព្រះវិហារនេះ ពួកគាហៀន៦១២ ហ្នឹង?

ពិន៖ ហ្នឹងហើយ ពីអានសេសមក ។

បូលី៖ វាយចូលពីច្រកអានសេសមក?

ពិន៖ បាទ! អានសេសមួយមុខសញ្ញា ប្រាសាទក៏មុខសញ្ញា ។

បូលី៖ ប្រាសាទព្រះវិហារក៏មុខសញ្ញាដែរ?

ពិន៖ បាទ! ហើយខ្ញុំក៏ចូលមកភ្នំដាច់ហ្នឹង បុកចូលទៅអូរស្មាយតាមត្រពាំងប្រាសាទនេះ អាហ្នឹងរួមគ្នាបុក សំដៅទៅអូរស្មាយទៅតំបន់ខ្មែរក្រហមឈរជើងនោះ ។

បូលី៖ ទៅពីអានសេស!

ពិន៖ មកមុខសញ្ញា ។

បូលី៖ អាហ្នឹងមុខសញ្ញាហើយណ៎ពូណ៎?

ពិន៖ បាទ!

បូលី៖ អាហ្នឹងវាយធ្វើអីគេអានសេសហ្នឹង?

ពិន៖ វាយឈរជើងតាមព្រំដែន ។

បូលី៖ វាយឈរជើងតាមព្រំដែនតែម្ដង?

ពិន៖ បាទៗ! ហើយព្រះវិហារ គ្រាន់តែមកចុះចូលទៅ ទៅទាំងអស់ហ្នឹង ហើយទំនប់ដាច់យើងផ្ដោះទៅអូរស្មាយ ។

បូលី៖ វាយចូលតាមច្រកផ្លូវណាវិញ?

ពិន៖ ទំនប់ដាច់វាយចូលពីកើតមកវិញ ពីកន្ទួតស្អាងមក ។ ព្រះវិហារក៏ចេញមកពីហ្នឹងទៅ!

បូលី៖ ព្រះវិហារក៏ចេញពីក្រាំងប៉ោលទៅវិញដែរ?

ពិន៖ រៀបនៅជាំក្សាន្តនោះ ។

បូលី៖ រៀបផែនការនៅជាំក្សាន្តនោះ?

ពិន៖ បាទ! ហ្នឹងឯងចែកមុខសញ្ញានៅឯ ។

បូលី៖ ផែនការយើងរៀបនៅឯជាំក្សាន្តនេះទេពូ?

ពិន៖ បាទ!

បូលី៖ ហើយវាយយកអានសេសមួយ ហើយបានវាយយកព្រះវិហារ?

ពិន៖ បាទ!

បូលី៖ ហើយបានវាយចូលតាមសែន មក?

ពិន៖ ទំនប់ដាច់ ។

បូលី៖ ទី៤អីគេពួ ទី៤ ។

ពិន៖ មកត្រពាំងប្រាសាទនេះ ។

បូលី៖ ទី៤វាយត្រពាំងប្រាសាទនេះ?

ពិន៖ ហ្នឹងហើយ! ត្រពាំងប្រាសាទ ហើយបានឈានទៅអន្លង់វែងទៀត ទៅចាប់ដៃគ្នានៅនោះជាមួយកងពលលេខ២ កងពលខាងតាអ៊ុយ! អ៊ុយ សុភាព ។

ពិន៖ អ៊ុយ សុភាព?

បូលី៖ មួយខាងអន្លង់វែងហ្នឹង គេមានក្រុមខ្មែរក្រហមគេមានទៀត?

ពិន៖ ហ្នឹងហើយ!

បូលី៖ (ស្តាប់ពុំបាន) តាពឹម!

ពិន៖ បាទ! ហ្នឹងហើយ ។

បូលី៖ ខាងហ្នឹង គេម៉ុំ គេវាយចូលពីនោះមកវិញ?

ពិន៖ បាទ! ពីសៀមរាបមកវិញ វាភ្ជាប់ពីសៀមរាប ។

បូលី៖ ពេលហ្នឹងរដ្ឋាភិបាលមាន តែរថក្រោះទេដួយវាយ ឬក៏មានអេលីកុបទ័រដែរ ឬយន្តហោះអីដែរ?

ពិន៖ អេលីកុបទ័រ គ្រាន់តែដឹកលជញ្ជូនធម្មតា មិនមាន ទ័ពប្រយុទ្ធទេ ។ (ស្តាប់ពុំបាន) មានឧត្តម្ភភេកជ្ជៈ ដឹកជញ្ជូនទេ ។

បូលី៖ គេមានបែកចែកការដឹកនាំទេពួមួយៗណា ឧទាហរណ៍វាយ?

ពិន៖ បែងចែកតា ។

បូលី៖ ពីនាំគេអ្នកដឹកនាំ ទិសទីមួយខាងអានសេស ។

ពិន៖ អានសេស ខាងរដ្ឋាភិបាល មិនដឹងខាងពីណា គេទេ ។ ប៉ុន្តែ មកដល់កម្លាំងខាងខ្ញុំ គាត់ស្លាប់ហើយ ។

បូលី៖ ពីណាគេ?

ពិន៖ ហើយតាលាយ កាលហ្នឹង ។ ខ្មោចតាឡាយ! នាំទៅ ។

បូលី៖ តាឡាយអតីតខ្មែរក្រហមដែរ?

ពិន៖ បាទ!

បូលី៖ គាត់ធ្វើអីតាឡាយ អតីតគាត់ជានៅខ្មែរក្រហម?

ពិនៈ  គាត់កាលនោះនៅវរសេនាធំដែរ ។

បូលីៈ កងពលលេខ?

ពិនៈ  លេខ៨០២ដែរ ។

បូលីៈ ចឹងតាឡាយជាអ្នកដឹកនាំវាយកម្លាំង?

ពិនៈ  បាទ! ចូលទៅជាមួយរដ្ឋាភិបាល ហើយចាំគាត់អ្នកដឹកនាមកម្លាំងខាងហ្នឹង ចូលតាមអានសេស ។ ដល់ឥលូវគាត់ស្លាប់ហើយ ស្លាប់ដោយចរាចរណ៍ ជិះតែកងទេណា ម៉ូតូ បុកទៅគាត់ស្លាប់ទៅ ។

បូលីៈ ចុះតាជុំ តាកែវ អី?

ពិនៈ  ហ្នឹងហើយ តាជុំអី កែវអីគាត់អ្នកបញ្ជា គាត់អ្នកអត់ប្រយុទ្ធលើសមរភូមិទេ ។ គាត់នៅពីក្រោយ ។

បូលីៈ អ៊ូ! បញ្ជាពីក្រោយទេ?

ពិនៈ  បាទ! គាត់បញ្ជាពីក្រោយ ។

បូលីៈ អ្នកដែលដឹកនាំផ្ទាល់ តាឡាយ?

ពិនៈ  តាឡាយខាងអានសេស ហើយដល់ នែ៎ក ខ្ញុំឡូទៅឡើងតាសាន ឡូតាមូល ហើយឡូនឿនដឹកនាំកម្លាំងជាមួយរដ្ឋាភិបាល ទៅប្រាសាទ ដល់មកខ្ញុំ ហើយតាលាង លេងអីដឹកនាំកម្លាំងមកទំនប់ដាច់នេះ ។ សញ្ញាធំពីក្រោយនេះ អានេះវាច្រើនដែរ ។

បូលីៈ លាងនេះ គាត់ដឹកនាំមកខាង ទំនប់ដាច់, ចុះព្រះវិហារ ពូថាពីណាគេមិញ?

ពិនៈ  អ៊ូ! ឡូនឿន ហើយនិងតាមូល ចាស់ៗហើយ ។

បូលីៈ នឿន ហើយនិងមូល ។ វាយចូលត្រពាំងប្រាសាទនរណាគេ?

ពិនៈ  ត្រពាំងប្រាសាទ រួមសហការណ៍ជាមួយគ្នា ទាំងតាលាង ខាងអី ទាំងអស់គ្នា ជាមួយគ្នា ។

បូលីៈ វាយចូលមកតែម្តង?

ពិនៈ  បាទ!

បូលីៈ តាជាតិ តាជុំ ហើយហ្នឹងតាកែវ ក្រោយទេចឹង?

ពិនៈ  ក្រោយទេ ។

បូលីៈ ក្រោយនោះនៅឯណា?

ពិនៈ  នៅក្រោយគាត់បញ្ជានៅពីក្រោយ ឧទាហរណ៍ថា គាត់មកនៅជាំក្សាន្តហ្នឹង វាមកដោយកងទ័ពឡើងមកមុខ គាតកិលមកស្រអែនចឹងទៅណា! ដល់មកឈរជើង នៅទំនប់ដាច់ បានគ្រប់គ្រង

ទំនប់ដាច់បាន បានអីហើយ វាយទៅនៅដល់អូរស្វាយដល់ផ្លូវ បានគាត់ទៅនៅដល់ផ្លូវ ទៅនៅអីនោះ ។ កន្លែងទីបញ្ចារការរបស់កងពល ។

បូលីៈ ចិនគេវាយទៅមកណ៎ាពូណ៎ា?

ពិនៈ បាទ!

បូលីៈ ដូវមក យើងវាយនៅទំនប់ដាច់ ហើយបានវាយចូលមកអូរស្វាយ ហើយបានវាយទៅផ្លូវវិញ?

ពិនៈ បាទ! ផ្លូវ ។

បូលីៈ ចេះតែរុញមកណ៎ាពូណ៎ា

ពិនៈ ហ្នឹងហើយ! ចេះតែរុញទៅ

បូលីៈ បាទ! វាយនៅត្រពាំងប្រាសាទមក ហើយខាងនេះគេវាយចិនទៅផ្ទុបចេះ ។ ដល់តាម៉ុករត់មកនេះម៉េចកើត បើរដ្ឋាភិបាល ចិនមានតែរត់ឡើងទៅលើ ហ្លួណយ ។ ចិនប្រពន្ធកូនពូពេលណាបានដោះលែងមកវិញ?

ពិនៈ ពេលដែលប្រយុទ្ធគ្នាចុងក្រោយនោះបានគេឲ្យកាត់ទោសលើ ទៅហ្លួណយហ្នឹង គាត់អត់ទៅ! ពេលគាត់ដើរបន្តិច គាត់បែកដូវមកផ្ទះមកសម្បែង ចោលកូនជាមួយនៅផ្ទះនេះ ។ ចោលកូនពិការមួយខ្វិននៅរាល់ថ្ងៃ ។

បូលីៈ បកមកវិញមក! ពេលណាបានជួបគ្នាពូ?

ពិនៈ ដល់ខ្ញុំមក បានៗជួប ។ ដល់ខ្ញុំមកវាយហើយ បានៗជួប ។

បូលីៈ ដល់ជួបទៅ គាត់ប្រាប់ថាម៉េច ចាប់ដាក់គុកតែម្តង?

ពិនៈ បាទ! ទេ! ដឹងៗតាមពីនៅក្នុងវិទ្យុគេអូទាក់ទង ។

បូលីៈ ចាប់ដាក់គុក ឬក៏នៅតែមួយកន្លែងទេ?

ពិនៈ បាទ! ចុះគេយកទៅឃុំឃាំង គេមិនដាក់មួយកន្លែងហើយ ។ ប៉ុនអត់មានបន្ទប់ទេ ដាក់ហាលវាល ស្រែប្រាំង ដាក់ឲ្យមូលខាំ ។

បូលីៈ ហើយបាយទឹកទៅ?

ពិនៈ បាយ ទឹកខ្លួនឯង ។ ដឹកជញ្ជូនអង្ករយកទៅស៊ីទៅ ។

បូលីៈ ពូយល់ថាតាម៉ុកជាមនុស្សយ៉ាងម៉េចដែរ?

ពិនៈ ហ៎! ខ្ញុំដូចជាពិយល់ណាស់ចឹង ។ និយាយថា វាពិបាកយល់ ចង់និយាថា គាត់វាមយ៉ាងៗដែរចឹងណា ។ ប៉ុន្តែ ថាគាត់ ត្រូវធ្វើអីគាត់ គាត់ធ្វើហ្នឹង គាត់ក្តៅមួយដំណើរគាត់ទៅណា ។

បូលីៈ គាត់ជាមនុស្សល្អ ឬមួយជាមនុស្សអាក្រក់តាម៉ុក?

ពិនៈ ហ៎! តាមយល់ទៅ បើយើងមើលទៀតថាគាត់ជាមនុស្សល្អដែរ ប៉ុនដល់ការធ្វើដូចជាពាង តឹងតែងដែរណា៎ ។

បូលីៈ បើខ្ញុំសួរអ្នកអន្ទង់វែង ចាត់ទុកតាម៉ុកដូចជាឪពុកម្ដាយចឹង ដូចជាអ្នកអាណាព្យាបាលចឹង?

ពិនៈ ចុះគាត់គ្រប់គ្រងរួម ។

បូលីៈ ជាម៉ែជាឪ! តែឲ្យតែនិយាយតាម៉ុក ធ្លាប់សម្លាប់មនុស្ស សម្លាប់អី ដូចមិនដែរទេ ។ សម្រាប់ពូ ពូយល់ថាម៉េច គាត់បែបម៉េច មនុស្សតាម៉ុក?

ពិនៈ ទេ! ដូចខ្ញុំថាអីចឹង ខ្ញុំដូចពិបាកនិយាយ វាពិបាកថា យើងមើលទៅថាគាត់វិភាគទៅ ថាគាត់ជាមនុស្សល្អដែរណា ប៉ុន្តែការធ្វើអី គាត់ដូចច្រើនអត្តនោម័តិដែរណា ។

បូលីៈ ខ្ញុំដូចមានសំនួរ សុំសួរពូតែប៉ុណ្ណឹងទេ! អគុណពូរច្រើន ពូមានអីចង់បន្ថែមពីលើហ្នឹង ដែលខ្ញុំមិនបានសួរទេអឺ ។

ពិនៈ ទេ! ដូចមិនមានចង់ អីបន្ថែមទេ! ចង់ដូចមិនមានអីច្រើនទេ គ្រាន់តែថាជីវិតធ្លាប់ទទួលការវេទនា គ្រោះហ្នឹង គិតទៅវាច្រើនដែរ ភាពជាយុទ្ធជនធ្លាប់ដឹងហើយ ភាពជាអ្នកតូចវាមិនដែលចេះស្រួលទេ ប៉ុនគ្រាន់តែថាពេលដែលបែកបាក់ប្រពន្ធកូន ពេលដែលប្រពន្ធកូនជាប់គុក ខ្ញុំមានអារម្មណ៍មួយដែរ មានអារម្មណ៍ពេលដែលចូលរួមរដ្ឋាភិបាល ខ្ញុំតាំងចិត្ត ក្នុងឆាកជីវិតធ្វើកងទ័ព ធ្វើទាហាននេះ ខ្ញុំសុំលាឈប់ ឈប់តែម្ដង ខ្ញុំចង់និយាយថាក្នុងការ សច្ចា សីងថាស្បថណា មួយជីវិតវាមិនដែលមិនបានសុខ បានស្រួលសោះចឹង ។

បូលីៈ តាំងពីចូលបដិវត្តន៍?

ពិនៈ បាទ! មិនដែលបានស្រួលសោះ ចឹងថាឲ្យតែបានជួបជុំប្រពន្ធកូនខ្ញុំឈប់ ហើយខ្ញុំឈប់តាំងពីថ្ងៃជួប ខ្ញុំឈប់តែម្ដងសូម្បីតែកាំភ្លើងខ្លី ខ្ញុំឲ្យគេអស់ហើយ ឲ្យទៅកន្លែងអគ្គនោះមួយដើម ឲ្យទៅកងពលលេខ១ ឲ្យទៅអាស្នានោះមួយដើម អាហ្នឹងថ្មីសុទ្ធតែម្ដង កាំភ្លើងយាយទៀត កាំភ្លើងគ្រួសារខ្ញុំកាលនោះ មីង១គាត់មានឋានៈក៏គាត់បើកកាំភ្លើងបានដែរ កាំភ្លើងខ្លី ។

បូលីៈ ស្រី១ ឲ្យកាន់ភ្លើងដែរ?

ពិនៈ បាទ! កាន់តា និយាយមិនឲ្យកាន់យ៉ាងម៉េច! កាន់សម្រាប់ការពារ សភាពការ កើតមានកាំភ្លើងរបស់គាត់ ។ ខ្ញុំឲ្យអស់លើងតែម្ដងចប់តែម្ដង ខ្ញុំថាអត់ធ្វើអីផង ។ និយាយរួមដំបូងគ្រប់ កងពលទាំងអស់ ហ៎ កុំឲ្យនេះ ទាញនេះ ឃើញនេះ យកទៅពាក់សក្តិអីនោះ ទេ! ខ្ញុំដូចលាឈប់ហើយ ឈប់ ខ្ញុំថាជីវិត បានជួបប្រពន្ធកូន ធ្វើស្រែ មួយរនោរក៏ស៊ីដេកស្រួយដែរ គិតឃើញចឹងណា ជីដូនជីតាមក ឃើញចឹងវិញ ហើយឈប់ទៅក៏ ទៅកៅ តាជុំថាអើយ កុំឈប់អី មកធ្វើការនៅស្រុកទៅ ក៏រៀនស៊ីវិល ក៏រៀនទៅចឹង ។ សាកទៅធ្វើទៀតទៅ ក៏មក

ស៊ីវិលនៅអភិបាលរងស្រុក មុនដំបូងនៅប្រធានមន្ទីរសាលាស្រុក បន្ទាប់ពីប្រធានមន្ទីរមក បានមកអភិបាលរងស្រុកតាំងពីនេអ តាំងពីដូច២០០៧ បានឡើងអភិបាលរងស្រុក រហូតមក រហូតមកភ្ជាប់ក្រុមប្រឹក្សាស្រុកចឹងទៅ ដល់អភិបាលទៅក៏ចូលនិវត្តន៍ទៅ តែឥលូវ មិនទាន់ឃើញធ្លាក់កញ្ចប់ថវិការសង្គមកិច្ចផងនេះ ដល់ខែនេះហើយតាំងពី ខែ៦មក វាដាច់លុយហើយ ចេះតែធ្វើទៅយើងវាលមបាក ។

បូលី: លោកពូធ្លាប់ធ្វើអភិបាលរងស្រុកដែរ?

ពិន: បាទ! អភិបាលរងស្រុកនេះ ខ្ញុំធ្វើច្រើនឆ្នាំដែរ និយាយរួមអណ្តិតចៅហ្វាយស្រុក តាំងពីបងជុំ រហូតដល់បងកុសលទៀត បាទ! ចៅហ្វាយស្រុក ។ អស់ចៅហវាយស្រុកពីរ បានចូលនិវត្តន៍ទៀតខ្លួនឯង ។

បូលី: ស្រុកត្រពាំងប្រាសាទនេះ មានឈ្មោះតាំងពីតាម៉ុកមក?

ពិន: បាទ! មានតាំងពីនោះមក ។

បូលី: មិនមែនទើបតែបង្កើតទេ ពេលដែលយើងវាយបាន ៩៨?

ពិន: បាទ! អត់ទេ ។ គេចែកជាគណៈស្រុកហើយ គណៈស្រុកនេះគឺ មានតាស៊ិយ ត្រពាំងប្រាសាទនេះ តាស៊ិយ តាដលហើយនេះ បាទ! សុទ្ធតែចៅហ្វាយស្រុក ជំនាន់តាម៉ុកហើយ ។ តាសារី ស៊ិយ ។

បូលី: ហ្នឹងចៅហ្វាយស្រុកសម័យតាម៉ុក?

ពិន: បាទ! ចៅហ្វាយស្រុកតាម៉ុកហើយ ។

បូលី: ពីណាគេចៅហ្វាយស្រុក ជំនាន់ហ្នឹង?

ពិន: ដឹងនរណាគេទេ កាលហ្នឹង ។ ដឹងតាដល ប្រធាន ឬក៏តាស៊ិយទេ សុទ្ធតែសាខារបស់គាត់ហើយជំនាន់ហ្នឹង ព្រោះកងទ័ព ដឹងតែតួនាទីរបស់កងទ័ព ការគ្រប់គ្រងរបស់ប្រពន្ធកូនអី ខាងគេ ក្រោយគ្រប់គ្រងទៅណា អាហ្នឹង! អង្គភាពខ្ញុំ៨០១ មានវរសេនាធំប៉ុន្មានៗ មួយកងពល ហ្នឹងច្បាស់តែម្តង កងពលផ្សេងទៀត យើងអត់សូវស្គាល់ទេ ។

បូលី: ចុះពូដឹងគណស្រុកអន្លង់វែង សម័យតាម៉ុក ពីណាគេទេ?

ពិន: សម័យតាម៉ុក?

បូលី: បាទ!

ពិន: ដឹងពីណាគេទេ ។ អត់ដឹងច្បាស់ដែរ! សម័យហ្នឹងពីណាគេទេ ។

បូលី: គណស្រុកហ្នឹង គឺថាអត់ទាក់ទង?

ពិន: ហ៊ូ! ដូចអន្លង់វែង ខាងយាយវ៉ាន់ ខាងអីហ្នឹង?

បូលីៈ យាយរ៉ាន់?

ពិនៈ មិនមែនទេអី! មិនដឹងពីណាខ្លះកាលហ្នឹង ។ កាលហ្នឹងគេបែក ប៉ុនមិនដឹងពីណាៗគេទេ ។

បូលីៈ រំខានពូយូរហើយ! អគុណច្រើនពូ ។

ពិនៈ បាទ! សុខសប្បាយ ។

«ចប់»